# ច្បាប់
# ស្តីពី
# ព្រៃឈើ

នស/រកម/០៨០២/០១៦

# ព្រះរាជក្រម

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន

## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

## ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពី ការបង្កើតក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ

## ប្រកាសអោយប្រើ

ច្បាប់ស្តីពីព្រៃឈើ ដែលរដ្ឋសភាបានអនុម័តកាល ពីថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០០២ នាសម័យប្រជុំពេញអង្គលើកទី ៨ នីតិកាលទី ២ ហើយដែលព្រឹទ្ធសភា បានអនុម័តយល់ស្របតាមលើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០០២ នាសម័យប្រជុំពេញអង្គលើកទី ៧ នីតិកាលទី១ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ :

# ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះកំណត់ក្របខ័ណ្ឌនៃការគ្រប់គ្រង ការប្រមូលផល ការប្រើប្រាស់ ការអភិវឌ្ឍន៍និងការអភិរក្សព្រៃឈើនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

គោលបំណងនៃច្បាប់នេះគឺធានានូវការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាពដើម្បីផលប្រយោជន៍សង្គម សេដ្ឋកិច្ច និងបរិស្ថាន រួមទាំងការអភិរក្សជីវៈចម្រុះ និងមរតកវប្បធម៌ ។

**មាត្រា ២.-**

ច្បាប់នេះមានវិសាលភាពអនុវត្តលើរាល់ព្រៃឈើទាំងអស់ ទោះជាប្រភេទព្រៃនោះកើតឡើងដោយធម្មជាតិក្តី ឬដោយដាំក្តី ។

រដ្ឋធានាសិទ្ធិប្រើប្រាស់ជាប្រពៃណីនូវផល អនុផលព្រៃឈើរបស់សហគមន៍មូលដ្ឋានក្រោមបទប្បញ្ញត្តិនៃច្បាប់នេះ ឬច្បាប់ពាក់ព័ន្ធផ្សេងទៀត ។

**មាត្រា ៣.-**

ការគ្រប់គ្រងព្រៃឈើត្រូវស្ថិតនៅក្រោមដែនសមត្ថកិច្ចទូទៅនៃក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ ។

ការគ្រប់គ្រងព្រៃលិចទឹកស្ថិតនៅក្រោមច្បាប់មួយដោយឡែក ។

រដ្ឋផ្តល់សិទ្ធិគ្រប់គ្រងតំបន់ការពារធម្មជាតិដល់ក្រសួងបរិស្ថាន ក្រោមបទប្បញ្ញត្តិទាំងឡាយនៃច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ១៩៩៦ ព្រះរាជក្រឹត្យស្តីពីការបង្កើតនិងការកំណត់តំបន់ការពារធម្មជាតិ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ និងលិខិតបទដ្ឋានច្បាប់ផ្សេងទៀត ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទមានសិទ្ធិសហការធ្វើសកម្មភាពពង្រឹងការអនុវត្តន៍ច្បាប់ ចំពោះរាល់បទល្មើសព្រៃឈើដែលកើតមាននៅក្នុងតំបន់ការពារធម្មជាតិក្រោមការសម្របសម្រួលជាមួយក្រសួងបរិស្ថាន ស្របតាមបទប្បញ្ញត្តិដូចមានចែងក្នុងជំពូកទី ១៤ នៃច្បាប់នេះ ។ សកម្មភាពនេះនឹងមិនធ្វើឱ្យប៉ះពាល់ដល់ដែនសមត្ថកិច្ចគ្រប់គ្រងរបស់ក្រសួងបរិស្ថាន ដូចមានចែងក្នុងច្បាប់ស្តីពីកិច្ចការពារបរិស្ថាននិងការគ្រប់គ្រងធនធានធម្មជាតិឡើយ ។

**មាត្រា ៤.-**

ក្នុងការអនុវត្តន៍ច្បាប់នេះ រាល់ការសម្រេចរបស់រាជរដ្ឋាភិបាលដែលមានសក្តានុពលភាពចំពោះផលប៉ះពាល់ធ្ងន់ធ្ងរទៅលើប្រជាពលរដ្ឋទូទៅ លើជីវភាពសហគមន៍មូលដ្ឋាន និងលើធនធានព្រៃឈើនៃព្រះរាជាណាចក្រកម្ពុជាត្រូវមានការចូលរួមជាសាធារណៈ ។

សកម្មភាពចម្បងៗពាក់ព័ន្ធទៅនឹងប្រព័ន្ធមជ្ឈដ្ឋានព្រៃឈើ ដែលអាចបណ្តាលអោយមានផលប៉ះពាល់អាក្រក់ដល់សង្គម និងបរិស្ថាន ចាំបាច់ត្រូវមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងផលប៉ះពាល់សង្គម ដោយផ្អែកតាមក្រមបច្ចេកទេសគ្រប់គ្រងព្រៃឈើកម្ពុជា និងស្របតាមច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធម្មជាតិ ។ ឯកសារនៃ

ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងផលប៉ះពាល់សង្គមត្រូវផ្តល់ជូនសម្រាប់ការចូលរួមផ្តល់មតិជាសាធារណៈបាន ។

រាល់ការសម្រេចចុងក្រោយលើរាល់សកម្មភាពចម្បងៗ ពាក់ព័ន្ធទៅនឹងប្រព័ន្ធមជ្ឈដ្ឋានព្រៃឈើ រាជរដ្ឋាភិបាលត្រូវពិចារណាលើអនុសាសន៍ចុងក្រោយនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងផលប៉ះពាល់សង្គម ។ ការសម្រេចចុងក្រោយណាមួយក្រោមមាត្រានេះ រាជរដ្ឋាភិបាលអាចធ្វើការជូនដំណឹងជាសាធារណៈ ។

**មាត្រា ៥.-**

វាក្យស័ព្ទសំខាន់ៗដែលប្រើប្រាស់ និងមានអត្ថន័យសម្រាប់ច្បាប់នេះត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធនៃច្បាប់នេះ ។

## ជំពូកទី ២

## រដ្ឋបាលព្រៃឈើ

**មាត្រា ៦.-**

រដ្ឋបាលព្រៃឈើគឺជាអាជ្ញាធររដ្ឋាភិបាល ដែលចំណុះក្រោមក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ ក្នុងការគ្រប់គ្រងព្រៃឈើ និងធនធានព្រៃឈើស្របតាមគោលនយោបាយវិស័យព្រៃឈើជាតិ និងច្បាប់នេះ ។

រដ្ឋបាលព្រៃឈើមានរចនាសម្ព័ន្ធគ្រប់គ្រងចាត់តាំងមួយឯកភាពទូទាំងប្រទេសជាខ្សែរយៈបណ្តោយ ដែលបែងចែកជាថ្នាក់កណ្តាល អធិការដ្ឋាន ខ័ណ្ឌ ផ្នែក និង សង្កាត់ រដ្ឋបាលព្រៃឈើ ។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់រដ្ឋបាលព្រៃឈើ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

រដ្ឋបាលព្រៃឈើត្រូវបំពេញភារកិច្ចរបស់ខ្លួន ស្របតាមគោលការណ៍តម្លាភាពដោយធានានូវសិទ្ធិរបស់សាធារណជនដើម្បីចូលរួមក្នុងការធ្វើសេចក្តីសម្រេចចិត្តលើការគ្រប់គ្រង ការប្រើប្រាស់ប្រកបដោយនិរន្តរភាព និងការអភិរក្សព្រៃឈើ ។

**មាត្រា ៧.-**

រដ្ឋបាលព្រៃឈើត្រូវបំពេញនូវភារកិច្ចដូចតទៅ :

១-ធានាដល់ការគ្រប់គ្រងសម្បត្តិព្រៃឈើអចិន្ត្រៃយ៍ប្រកបដោយនិរន្តរភាពដោយដាក់បទបញ្ជាលើរាល់សកម្មភាពព្រៃឈើ ។

២-សិក្សាប្រមូលទិន្នន័យលើព្រៃឈើរដ្ឋទាក់ទងនឹងកត្តាវិទ្យាសាស្ត្រ សេដ្ឋកិច្ច សង្គម និងបរិស្ថាន ដើម្បីកំណត់នូវកំរិតផ្តល់ផលប្រកបដោយនិរន្តរភាព ។

៣-វាយតម្លៃព្រំប្រទល់ ធ្វើការចាត់ថ្នាក់ និងកំណត់ដែនព្រៃឈើ ដើម្បីបង្កើតផែនទីប្រើប្រាស់ដីសម្បត្តិព្រៃឈើអចិន្ត្រៃយ៍ ដោយសម្របសម្រួលជាមួយក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ អាជ្ញាធរដែនដី និងសហគមន៍មូលដ្ឋាន ។

៤-រៀបចំ និងអនុវត្តផែនការគ្រប់គ្រងព្រៃឈើជាតិនៅថ្នាក់នីមួយៗ នៃរដ្ឋបាលព្រៃឈើ ។

៥-បង្កើនការដាំដុះព្រៃឈើឡើងវិញលើដីព្រៃរេចរឹល និងដីព្រៃទំនេរ ។

៦-បង្កើនការអភិវឌ្ឍន៍កិច្ចព្រមព្រៀង និងកម្មវិធីសហគមន៍ព្រៃឈើដោយផ្តល់នូវជំនួយហិរញ្ញវត្ថុ និងបច្ចេកទេសដល់សហគមន៍តាមការសមស្រប ។

៧-អភិវឌ្ឍ និងអនុវត្តកម្មវិធីស្រាវជ្រាវ ការពារនិងថែរក្សាធនធានព្រៃឈើនិងសត្វព្រៃ ។

៨-ចាត់វិធានការសមស្របដើម្បីស្រាវជ្រាវ ទប់ស្កាត់ និងបង្ក្រាបរាល់ការបំផ្លិចបំផ្លាញព្រៃឈើ ភ្លើងឆេះព្រៃ និងការកាប់រានព្រៃឈើ ដោយធានាការអនុវត្តន៍ច្បាប់ប្រកបដោយប្រសិទ្ធភាព ។

៩-បង្កើនការអប់រំដល់ប្រជាពលរដ្ឋតាមរយៈកម្មវិធីដែលបង្ហាញពីសារៈសំខាន់ក្នុងការគ្រប់គ្រង ការពារថែរក្សាព្រៃឈើ ក៏ដូចជាចាត់វិធានការស្តារប្រព័ន្ធមជ្ឈដ្ឋានធម្មជាតិ និងថែរក្សាព្រៃឈើជាតិ ។

១០-បង្កើនកិច្ចសហប្រតិបត្តិការអន្តរជាតិ សំដៅពង្រឹងសមត្ថភាពការពារនិងអភិវឌ្ឍធនធានព្រៃឈើ ។

១១-ធានាការវាយតម្លៃទាន់ពេលវេលា និងពេញលេញនូវរាល់សកម្មភាពទាក់ទងនឹងព្រៃឈើដែលមានផលប៉ះពាល់អាក្រក់ដល់សង្គម និងបរិស្ថានមុនការឯកភាពលើសកម្មភាពទាំងនេះ ។

មន្ត្រីរដ្ឋបាលព្រៃឈើមានសិទ្ធិ និងភារកិច្ចដូចខាងក្រោម :

១-ត្រួតពិនិត្យការធ្វើអាជីវកម្មប្រមូលផល អនុផលព្រៃឈើក្នុងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ និងចំការដាំឈើរបស់រដ្ឋ ។

២-ត្រួតពិនិត្យការដឹកជញ្ជូនផល អនុផលព្រៃឈើ និងផលប្រមាញ់តាមមធ្យោបាយដឹកជញ្ជូនទាំងនានា ។

៣-ត្រួតពិនិត្យកន្លែងសន្និធិផល អនុផលព្រៃឈើ ទីតាំងលក់ផល អនុផលព្រៃឈើ ឬផលប្រមាញ់ ។

៤-ត្រួតពិនិត្យមូលដ្ឋានឧស្សាហកម្មឈើ រោងចក្រអារឈើ សិប្បកម្មកែច្នៃផល អនុផលព្រៃឈើ និងឡគ្រប់ប្រភេទដែលប្រើប្រាស់ផលអនុផលព្រៃឈើ ជាវត្ថុធាតុដើម ឬប្រភពថាមពលអំពីឈើ ។

៥-ត្រួតពិនិត្យអាជ្ញាប័ណ្ណ លិខិតអនុញ្ញាត និងឯកសារផ្សេងទៀតដែលតម្រូវឱ្យត្រួតពិនិត្យតាមច្បាប់នេះ ។

## ជំពូកទី៣

## និរន្តរភាពនៃការគ្រប់គ្រងព្រៃឈើ

### មាត្រា ៨.-

ការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព ត្រូវអនុវត្តស្របតាមគោលនយោបាយវិស័យព្រៃឈើជាតិ និងច្បាប់នេះ ។

ដើម្បីជំនួយឱ្យការសិក្សាស្រាវជ្រាវគោលនយោបាយវិស័យព្រៃឈើជាតិឱ្យមានប្រសិទ្ធភាព រាជរដ្ឋាភិបាលត្រូវបង្កើតគណៈកម្មាធិការជាតិរៀបចំគោលនយោបាយវិស័យព្រៃឈើជាតិដែលដឹកនាំដោយរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ និងមានសមាជិកពីក្រសួងពាក់ព័ន្ធនឹងវិស័យព្រៃឈើ ។ ផ្អែកតាមអនុសាសន៍របស់គណៈកម្មាធិការជាតិរៀបចំគោលនយោបាយវិស័យព្រៃឈើជាតិ រាជរដ្ឋាភិបាលត្រូវកំណត់នូវគោលនយោបាយវិស័យព្រៃឈើជាតិ ។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិរៀបចំគោលនយោបាយវិស័យព្រៃឈើជាតិត្រូវកំណត់ដោយអនុក្រឹត្យ ។

គោលនយោបាយវិស័យព្រៃឈើជាតិ អាចសើរើដោយរាជរដ្ឋាភិបាលដោយផ្អែកតាមអនុសាសន៍របស់គណៈកម្មាធិការជាតិរៀបចំគោលនយោបាយវិស័យព្រៃឈើជាតិ ក្នុងលក្ខខណ្ឌផ្លាស់ប្តូរនៃស្ថានភាពវិស័យព្រៃឈើតាមគោលការណ៍ដែលនាំមកនូវដំណោះស្រាយដើម្បីរក្សានិរន្តរភាពនៃ ការគ្រប់គ្រងព្រៃឈើ ។

**មាត្រា ៩.-**

រដ្ឋបាលព្រៃឈើត្រូវរៀបចំផែនការគ្រប់គ្រងវិស័យព្រៃឈើជាតិ ស្របតាមគោលនយោបាយវិស័យព្រៃឈើជាតិ ដោយមានការចូលរួមទូលំទូលាយពីគ្រប់អាជ្ញាធរពាក់ព័ន្ធនឹងសហគមន៍មូលដ្ឋាន ដែលអនុលោមតាមមាត្រា ៤នៃច្បាប់នេះ ។

ផែនការគ្រប់គ្រងវិស័យព្រៃឈើជាតិត្រូវសំរេចដោយរាជរដ្ឋាភិបាលសំរាប់រយៈពេលវែង ដើម្បីកំណត់អាទិភាព និងសកម្មភាពគ្រប់គ្រងព្រៃឈើ ។ ផែនការគ្រប់គ្រងវិស័យព្រៃឈើជាតិត្រូវធ្វើការពិនិត្យ និងសើរើរៀងរាល់ ៥ឆ្នាំ ម្តង ដើម្បីឆ្លុះបញ្ចាំងពីលក្ខខណ្ឌនិងកាលៈទេសៈផ្លាស់ប្តូរ ។ គណៈកម្មាធិការជាតិរៀបចំគោលនយោបាយវិស័យព្រៃឈើជាតិត្រូវផ្តល់អនុសាសន៍ជូនរាជរដ្ឋាភិបាលលើផែនការគ្រប់គ្រងវិស័យព្រៃឈើជាតិដែលបានសើរើ ។

ផែនការគ្រប់គ្រងវិស័យព្រៃឈើជាតិ ត្រូវលើកឡើងនូវសមាសភាគដូចតទៅ :

១-ពិនិត្យកត្តារូបសាស្ត្រ បរិស្ថាន និងសង្គមទាក់ទងនឹងធនធានព្រៃឈើនៅគ្រប់ថ្នាក់នៃរដ្ឋបាលព្រៃឈើ ។

២-ប៉ាន់ស្មានបរិមាណផល អនុផលព្រៃឈើគ្រប់លំដាប់ថ្នាក់ ។

៣-កំណត់ផ្ទៃដីតំបន់ព្រៃឈើ តំបន់ត្រូវដាំឈើឡើងវិញ និងព្រៃសហគមន៍ ។

៤-ពិនិត្យកម្មវិធី និងប្រតិទិនសកម្មភាពលំអិតលើការងាររៀបចំព្រៃឈើ និងរុក្ខវប្បកម្ម ។

៥-អភិវឌ្ឍកម្មវិធីនៃការធ្វើអន្តរាគមន៍ ដល់ភាគីពាក់ព័ន្ធក្នុងការគ្រប់គ្រង និងប្រើប្រាស់ព្រៃឈើរដ្ឋ និងឯកជន

៦-អភិវឌ្ឍកម្មវិធីសម្រាប់អភិវឌ្ឍន៍ឧស្សាហកម្មព្រៃឈើ ទីផ្សារផល អនុផលព្រៃឈើ ។

៧-អភិវឌ្ឍកម្មវិធីស្រាវជ្រាវ ស្តីពីការអភិវឌ្ឍន៍បច្ចេកវិជ្ជា និងវិទ្យាសាស្ត្រព្រៃឈើ ។

៨-បង្កើន និងពង្រីកចំណេះដឹងពីព្រៃឈើដោយអញ្ជើញការចូលរួមពីសហគមន៍មូលដ្ឋានក្នុងការគ្រប់គ្រងប្រើប្រាស់ និងការពារព្រៃឈើ ។

៩-អភិវឌ្ឍធនធានមនុស្ស និងមធ្យោបាយសម្ភារៈចាំបាច់ ដើម្បីសម្រេចលើសកម្មភាពដែលបានគ្រោងនៅក្នុងកម្មវិធី ។

១០-ពង្រឹងស្ថាប័នគ្រប់គ្រងវិស័យព្រៃឈើនៅគ្រប់ថ្នាក់ កែលំអ និងពង្រឹងការអនុវត្តន៍ច្បាប់ ។

១១-ពង្រឹងកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច ជំនួយបច្ចេកទេស ក្នុងតំបន់ និងក្រៅតំបន់ ក្នុងកិច្ចការពារ និងអភិវឌ្ឍន៍ធនធានព្រៃឈើ ។

១២-ឧបត្ថម្ភគាំទ្ររាល់កម្មវិធីទាំងឡាយណា ដែលជំរុញឱ្យមានការអនុវត្តន៍គោលនយោបាយវិស័យព្រៃឈើជាតិ ។

ផ្អែកតាមអនុសាសន៍របស់គណៈកម្មាធិការជាតិរៀបចំគោលនយោបាយវិស័យព្រៃឈើជាតិ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវដាក់របាយការណ៍ប្រចាំឆ្នាំស្តីពីការអនុវត្តន៍ នូវគោលបំណងនៃផែនការគ្រប់គ្រងវិស័យព្រៃឈើជាតិ ជូនរាជរដ្ឋាភិបាល ។ របាយការណ៍នេះ ត្រូវផ្តល់ជូនជាសាធារណៈតាមការស្នើសុំ ។

## ជំពូកទី ៤

## សម្បត្តិព្រៃឈើអចិន្ត្រៃយ៍

### មាត្រា ១០.-

សម្បត្តិព្រៃឈើអចិន្ត្រៃយ៍រួមមាន :

១-ព្រៃបម្រុងទុកអចិន្ត្រៃយ៍ ។

២-ព្រៃឯកជន ។

ព្រៃបម្រុងទុកអចិន្ត្រៃយ៍រួមមានបីប្រភេទ :

១-ព្រៃផ្តល់ផលត្រូវបានរក្សាទុកសម្រាប់ផលិតកម្មផល អនុផលព្រៃឈើប្រកបដោយនិរន្តរភាពដែលក្នុងនោះមុខងារការពារត្រូវចាត់ទុកជាអាទិភាពបន្ទាប់ ។ ព្រៃផ្តល់ផលមានជាអាទិ៍ :

-ព្រៃសម្បទាន

-ព្រៃផ្តល់ផលក្រៅពីព្រៃសម្បទាន

-ព្រៃឈើត្រូវស្តារឡើងវិញ

-ផ្ទៃដីព្រៃបម្រុងទុកសម្រាប់ដាំដើមឈើឡើងវិញ ឬចំការព្រៃឈើ

-ផ្ទៃដីព្រៃបម្រុងទុកសម្រាប់បន្តពូជព្រៃឈើ

-ផ្ទៃដីព្រៃរេចរឹល

-ព្រៃសហគមន៍ក្រោមកិច្ចព្រមព្រៀង ។

២-ព្រៃការពារត្រូវបានរក្សាទុកជាចម្បង ដើម្បីការពារប្រព័ន្ធមជ្ឈដ្ឋាន និងធនធានធម្មជាតិ ។ ព្រៃការពារមានជាអាទិ៍ :

-ព្រៃបម្រុងទុកសំរាប់ប្រព័ន្ធមជ្ឈដ្ឋានពិសេស

-ព្រៃសម្រាប់សិក្សាស្រាវជ្រាវ

-ព្រៃនិយតកម្មប្រភពទឹក

-ព្រៃការពារទីជំរាល

-ព្រៃលំហែកំសាន្ត

-សួនរុក្ខជាតិ

-ព្រៃជំនឿសាសនា ។

ព្រៃការពារនេះអាចអនុញ្ញាតឱ្យប្រមូលផល អនុផលព្រៃឈើជាលក្ខណៈប្រពៃណីដែលមានផលប៉ះពាល់ទាបដោយ

សហគមន៍មូលដ្ឋាន ។

៣-ផ្ទៃដីព្រៃសម្រាប់ផ្ទេរដើម្បីគោលបំណងអភិវឌ្ឍផ្សេងទៀត ជាដីទំនេរដុះរុក្ខជាតិព្រៃបន្ទាប់បន្សំដែលមិនទាន់ស្ថិតនៅក្នុងការប្រើប្រាស់របស់វិស័យណាមួយនៅឡើយ ត្រូវតែដាក់ឱ្យស្ថិតនៅក្នុងចំណាត់ថ្នាក់នៃព្រៃបម្រុងទុកអចិន្ត្រៃយ៍ រហូតដល់មានការសម្រេចឱ្យប្រើប្រាស់ និងអភិវឌ្ឍសម្រាប់គោលបំណងផ្សេងទៀត ដោយរាជរដ្ឋាភិបាល ។

ព្រៃឯកជនត្រូវថែរក្សាដោយម្ចាស់កម្មសិទ្ធិ និងមានសិទ្ធិទទួលផលប្រយោជន៍ក្នុងការអភិវឌ្ឍន៍ និងប្រមូលផលប្រើប្រាស់ លក់ចែកចាយផលិតផលរបស់ខ្លួនដោយផ្ទាល់ ។

**មាត្រា ១១.-**

សម្បត្តិព្រៃឈើអចិន្ត្រៃយ៍ត្រូវគ្រប់គ្រងក្នុងគោលបំណងបង្កើនជាអតិបរមានូវប្រយោជន៍សង្គម សេដ្ឋកិច្ច បរិស្ថាន និងមរតកវប្បធម៌សម្រាប់ព្រះរាជាណាចក្រកម្ពុជា និងប្រជាពលរដ្ឋកម្ពុជាស្របនឹងគោលការណ៍គ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទត្រូវចាត់ថ្នាក់ចុះបញ្ជិកា និងកំណត់ព្រំប្រទល់ព្រៃឈើទាំងអស់នៅក្នុងសម្បត្តិព្រៃឈើអចិន្ត្រៃយ៍ ។ ក្នុងការអនុវត្តន៍នូវសកម្មភាព ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនឹងធ្វើការសម្របសម្រួលជាមួយសហគមន៍មូលដ្ឋាន អាជ្ញាធរពាក់ព័ន្ធ និងក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ដើម្បីជួយដល់ដំណើរការចុះបញ្ជិកាកម្មសិទ្ធិដីសហគមន៍ជនជាតិដើមភាគតិច និងការរៀបចំផែនទីប្រើប្រាស់ដីថ្នាក់ជាតិ ។

គ្រប់ព្រៃឈើដែលបានចាត់ថ្នាក់នៅក្នុងព្រៃបំរុងទុកអចិន្ត្រៃយ៍ត្រូវបានរៀបចំ និងគ្រប់គ្រង ស្របតាមគោលបំណងនៃផែនការគ្រប់គ្រងវិស័យព្រៃឈើជាតិ ។

នីតិវិធី ការបង្កើត ការចាត់ថ្នាក់ និងការចុះបញ្ជិកាសម្បត្តិព្រៃឈើអចិន្ត្រៃយ៍ ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ១២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា មានសិទ្ធិអំណាចរំសាយចំណាត់ថ្នាក់ព្រៃឈើណាមួយពីព្រៃបម្រុងទុកអចិន្ត្រៃយ៍ ។ ការសម្រេចបែបនេះត្រូវស្ថិតនៅក្នុងផលប្រយោជន៍សាធារណៈ និងមានសង្គតិភាពជាមួយគោលនយោបាយវិស័យព្រៃឈើជាតិ ផែនការគ្រប់គ្រងវិស័យព្រៃឈើជាតិ និងទិន្នន័យបច្ចេកទេស សង្គម សេដ្ឋកិច្ចដែលផ្តល់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។ ស្របតាមបទប្បញ្ញត្តិដូចមានចែងក្នុងច្បាប់នេះ ការរំសាយចំណាត់ថ្នាក់ណាមួយនៃព្រៃបម្រុងទុកអចិន្ត្រៃយ៍ សម្រាប់គោលបំណងមិនមែនព្រៃឈើត្រូវពិចារណាលើអាទិភាព ដូចខាងក្រោម :

១-ផ្ទៃដីព្រៃសម្រាប់ផ្ទេរដើម្បីគោលបំណងអភិវឌ្ឍផ្សេងទៀត ។

២-ដីព្រៃបម្រុងទុកអចិន្ត្រៃយ៍ផ្សេងទៀតដែលតម្រូវការបច្ចុប្បន្នខ្ពស់ជាងតម្រូវការដែលកំណត់កន្លងមក ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទអាចស្នើសុំរាជរដ្ឋាភិបាលកំណត់រកផ្ទៃដីព្រៃទំនេរផ្សេងទៀត ដើម្បីជំនួសផ្ទៃដីព្រៃបម្រុងទុកអចិន្ត្រៃយ៍ដែលបានរំសាយក្នុងគោលបំនងការពារ និងដាំព្រៃឡើងវិញ ដើម្បីរក្សាគម្របជាអចិន្ត្រៃយ៍ ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទអាចស្នើសុំរាជរដ្ឋាភិបាលសំរេចធ្វើការផ្លាស់ប្តូរចំណាត់ថ្នាក់ព្រៃណាមួយនៅក្នុងដែនព្រៃបំរុងទុកអចិន្ត្រៃយ៍ ដោយផ្អែកលើទិន្នន័យសិក្សាថ្មី និងមុខងាររបស់ដីព្រៃនោះ ។

រាល់ការសម្រេចរំសាយចំណាត់ថ្នាក់ព្រៃឈើដូចមានចែងក្នុងកឋាខ័ណ្ឌទី១ និងការផ្លាស់ប្តូរចំណាត់ថ្នាក់ព្រៃឈើដូចមានចែងក្នុងកឋាខ័ណ្ឌទី៣ នៃមាត្រានេះ ត្រូវកំណត់ដោយអនុក្រឹត្យ ។

## ជំពូកទី ៥
## ការគ្រប់គ្រងព្រៃសម្បទាន

### មាត្រា ១៣.-

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា អាចផ្តល់តំបន់ព្រៃផ្តល់ផលដែលនៅទំនេរ ស្របតាមផែនការគ្រប់គ្រងវិស័យព្រៃឈើជាតិទៅជាព្រៃសម្បទាន ដោយដាក់ឱ្យដេញថ្លៃជាសាធារណៈ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខប្រមាញ់ និងនេសាទ ក្រោយពីបានពិគ្រោះយោបល់ជាមួយបណ្តាលក្រសួងពាក់ព័ន្ធ អាជ្ញាធរដែនដី និងសហគមន៍មូលដ្ឋានរួចហើយ ។

សំណុំឯកសារ និងនីតិវិធីនៃការដេញថ្លៃជាសាធារណៈចំពោះការផ្តល់ព្រៃសម្បទានត្រូវកំណត់ដោយអនុក្រឹត្យស្តីពីការគ្រប់គ្រងព្រៃសម្បទាន។

### មាត្រា ១៤.-

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាមានសិទ្ធិអំណាចចុះកិច្ចព្រមព្រៀងព្រៃសម្បទានជាមួយវិនិយោគិន ឬនីតិបុគ្គលណាមួយដោយការផ្តល់សម្បទាននេះ ត្រូវមានសង្គតិភាពជាមួយគោលនយោបាយវិស័យព្រៃឈើជាតិ ផែនការគ្រប់គ្រង វិស័យព្រៃឈើជាតិ និងបទប្បញ្ញត្តិទាំងឡាយនៃច្បាប់នេះ ។

ការដេញថ្លៃជាសាធារណៈ ត្រូវតែអនុវត្តជាមូលដ្ឋាននៅមុនពេលរាជរដ្ឋាភិបាលចុះកិច្ចព្រមព្រៀងព្រៃសម្បទានដោយអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះ និងអនុក្រឹត្យស្តីពីការគ្រប់គ្រងព្រៃសម្បទាន ។

គណៈកម្មការដេញថ្លៃព្រៃសម្បទានត្រូវផ្តល់នូវកាលានុវត្តិភាព និង ការពិចារណាជូនអ្នកដេញថ្លៃគ្រប់រូប ដោយមានលក្ខណសម្បត្តិគ្រប់គ្រាន់ និងត្រូវជូនដំណឹងអំពីការដេញថ្លៃជាសាធារណៈឱ្យបានទាន់ពេលវេលា ជាពិសេសដល់ប្រជាពលរដ្ឋមូលដ្ឋានក្នុងតំបន់ដែលដាក់ជាព្រៃសម្បទាន ។

បេក្ខភាពក្រុមហ៊ុនដេញថ្លៃ ត្រូវភ្ជាប់រាល់ឯកសារដេញថ្លៃជាមួយនឹងលិខិតថ្លែងការណ៍របស់ក្រុមហ៊ុន ដែលចែងលំអិតអំពីការប្រព្រឹត្តល្អលើកិច្ចព្រមព្រៀងព្រៃសម្បទានដែលបានអនុវត្តកន្លងមក ទោះក្នុងប្រទេសក្តី ឬក្រៅប្រទេសក្តីដោយមានភស្តុតាងធានាអះអាងផង ។

### មាត្រា ១៥.-

ព្រៃសម្បទានិកមានសិទ្ធិដំណើរការគ្រប់គ្រង និងប្រមូលផល អនុផលព្រៃឈើនៅក្នុងដែនដីព្រៃសម្បទានរបស់ខ្លួនដោយធានាថា ប្រតិបត្តិការទាំងនេះនឹងមិនប៉ះពាល់ដល់ :

១-សិទ្ធិប្រើប្រាស់ជាប្រពៃណីដែលអនុវត្តនៅលើទឹកដីកម្មសិទ្ធិរបស់សហគមន៍ជនជាតិដើមភាគតិច ដែលបានចុះបញ្ជិកាដោយរដ្ឋស្របតាមច្បាប់ភូមិបាល ។

២-សិទ្ធិចេញ-ចូល និងសិទ្ធិប្រើប្រាស់ជាប្រពៃណី អនុវត្តដោយសហគមន៍ដែលមានទីតាំងក្នុង ឬក្បែរព្រៃសម្បូ

ទាន ។

**មាត្រា ១៦.-**

ខ្លឹមសារកិច្ចព្រមព្រៀងព្រៃសម្បទានក្នុងកិរិតអប្បរមាត្រូវមាន :

១-កាលបរិច្ឆេទនៃការផ្តល់ព្រៃសម្បទាន និងរយៈពេលនៃការផ្តល់ ។

២-ទីតាំងព្រៃសម្បទានដែលកំណត់បង្ហាញនូវអត្តសញ្ញាណដីកម្មសិទ្ធិសហគមន៍ជនជាតិដើមភាគតិច តំបន់ព្រៃសហគមន៍ តំបន់គ្រប់គ្រងពិសេស និងផ្ទៃដីព្រៃដែលអាចប្រមូលផលបាន ។

៣-សេចក្តីថ្លែងការណ៍ជាលាយលក្សណ៍អក្សរថា ព្រៃសម្បទានិកត្រូវគោរព និងមិនជ្រៀតចូលធ្វើការប្រមូលផល អនុផលព្រៃឈើក្នុងតំបន់គ្រប់គ្រងពិសេសតំបន់កម្មសិទ្ធិសហគមន៍ជនជាតិដើមភាគតិច និងព្រៃសហគមន៍ឡើយ ។

៤-ប្រភេទ និងបរិមាណផល អនុផលព្រៃឈើអនុញ្ញាតឱ្យប្រមូល និងវិធីសាស្ត្រគណនាបរិមាណដែលអាចដកហូតបាន ។

៥-ការបរិយាយពីកាតព្វកិច្ចរបស់ព្រៃសម្បទានិកក្នុងការកសាង និងការអនុវត្តន៍ គំរោងផែនការណ៍គ្រប់គ្រងព្រៃឈើកម្រិតព្រៃសម្បទាន ព្រៃគុប និងប្លុកប្រមូលផល ។

៦-លក្ខខណ្ឌផ្សេងទៀត ដែលកំណត់ដោយរាជរដ្ឋាភិបាលកម្ពុជា ឬរដ្ឋបាលព្រៃឈើពាក់ព័ន្ធទៅនឹងព្រៃសម្បទាន ។

**មាត្រា ១៧.-**

កិច្ចព្រមព្រៀងព្រៃសម្បទាន មិនត្រូវកំណត់ឱ្យលើសរយៈពេលសាមសិប (៣០) ឆ្នាំឡើយ ។

កិច្ចព្រមព្រៀងព្រៃសម្បទានអាចបញ្ឈប់ នៅពេលណាដែលរាជរដ្ឋាភិបាលបានរកឃើញថា ព្រៃសម្បទានិកបានរំលោភធ្ងន់ធ្ងរលើបណ្តាលក្ខខណ្ឌដែលតម្រូវឱ្យបញ្ឈប់ ដូចមានចែងក្នុងអនុក្រឹត្យស្តីពីការគ្រប់គ្រងព្រៃសម្បទាន ។

ព្រៃសម្បទានិកមានសិទ្ធិស្នើសុំការពន្យល់ពីមូលហេតុនៃការសម្រេចលុបចោលកិច្ចព្រមព្រៀងព្រៃសម្បទាន មុនកាលកំណត់ដោយរដ្ឋាភិបាល ។ វិធានដោះស្រាយវិវាទ ត្រូវស្របតាមលក្ខខណ្ឌ ដូចមានចែងក្នុងកិច្ចព្រមព្រៀងព្រៃសម្បទាន និងច្បាប់ជាធរមាន ។

ដោយផ្អែកតាមការវាយតំលៃលើការអនុវត្តន៍របស់ព្រៃសម្បទានិកដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជរដ្ឋាភិបាលអាចអនុគ្រោះបន្តកិច្ចព្រមព្រៀងបាន ហើយរយៈពេលបន្តនេះ មិនត្រូវលើសពីរយៈពេលកំណត់ក្នុងកិច្ចព្រមព្រៀងព្រៃសម្បទានដំបូងឡើយ ។

**មាត្រា ១៨.-**

ការរៀបចំផែនការគ្រប់គ្រងព្រៃសម្បទានគ្រប់កម្រិត ត្រូវទទួលខុសត្រូវដោយព្រៃសម្បទានិក តាមគោលការណ៍ណែនាំដែលមានចែងក្នុងក្បួនធ្វើផែនការគ្រប់គ្រងព្រៃសម្បទានក្រមបច្ចេកទេសអនុវត្តប្រមូលផលព្រៃឈើនៅកម្ពុជា និងប្រការទាំងឡាយដែលមានចែងក្នុងកិច្ចព្រមព្រៀងសម្បទាន ។

ព្រៃសម្បាទានិកត្រូវរៀបចំផែនការគ្រប់គ្រងព្រៃសម្បទានតាមកម្រិតដូចខាងក្រោម :

១-ផែនការគ្រប់គ្រងរយៈពេលវែងសម្រាប់ព្រៃសម្បទានទាំងមូល ។

២-ផែនការប្រមូលផល អនុផលព្រៃឈើប្រចាំឆ្នាំសម្រាប់កម្រិតព្រៃគុបនីមួយៗ ។

៣-ផែនការគ្រប់គ្រងប្លុកប្រមូលផលសម្រាប់ការប្រមូលផលប្រចាំឆ្នាំនីមួយៗ ។

ផែនការគ្រប់គ្រងព្រៃសម្បទាន និងការសើរើត្រូវកំណត់តាមវិធានខាងក្រោម :

១-ផែនការគ្រប់គ្រងព្រៃសម្បទានត្រូវសម្រេចដោយរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តាមសំណើរបស់ប្រធានរដ្ឋបាលព្រៃឈើ ។ ផែនការនេះត្រូវពិនិត្យសើរើរៀងរាល់ប្រាំ (៥) ឆ្នាំម្តង ។

២-ផែនការប្រមូលផលកម្រិតព្រៃគុបប្រចាំឆ្នាំ និងផែនការគ្រប់គ្រងប្លុកប្រមូលផលត្រូវសម្រេចដោយប្រធានរដ្ឋបាលព្រៃឈើ ។

### មាត្រា ១៩.-

ព្រៃសម្បទានិកទាំងអស់ត្រូវតែដាក់បញ្ចូលក្នុងផែនការគ្រប់គ្រងព្រៃសម្បទាននូវការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងផលប៉ះពាល់សង្គម ស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ និងលិខិតបទដ្ឋាននានាស្តីពីការគ្រប់គ្រងព្រៃសម្បទាន ។

ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងផលប៉ះពាល់សង្គមលើព្រៃសម្បទានដែលជាផ្នែកមួយនៃផែនការគ្រប់គ្រងព្រៃសម្បទានត្រូវរៀបចំដោយព្រៃសម្បទានិក និងត្រូវបានពិនិត្យ និងវាយតម្លៃដោយក្រសួងបរិស្ថាន មុននឹងសម្រេចយល់ព្រមដោយរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទត្រូវធានាការចូលរួមផ្តល់មតិជាសាធារណៈលើផែនការគ្រប់គ្រង ព្រៃសម្បទាន និងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងផលប៉ះពាល់សង្គម មុនពេលការសម្រេចចេញលិខិតអនុញ្ញាតប្រមូលផល អនុផលព្រៃឈើ ។

## ជំពូកទី ៦

## ការគ្រប់គ្រងព្រៃផ្តល់ផលក្រៅពីព្រៃសម្បទាន និងព្រៃការពារ

### មាត្រា ២០.-

ព្រៃផ្តល់ផលក្រៅពីព្រៃសម្បទានត្រូវបានគ្រប់គ្រងដើម្បីបំរើជាអាទិភាពនូវសេចក្តីត្រូវការផល អនុផលព្រៃឈើប្រចាំឆ្នាំក្នុងស្រុក ។ ផល អនុផលព្រៃឈើទាំងនេះអាចធ្វើការនាំចេញបាន នៅពេលណាដែលការផ្គត់ផ្គង់លើសពីតម្រូវការប្រើប្រាស់ក្នុងស្រុក ដោយមានការសម្រេចពីរាជរដ្ឋាភិបាល តាមសំណើរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

### មាត្រា ២១.-

ប្រធានផ្នែករដ្ឋបាលព្រៃឈើមានភារកិច្ចរៀបចំ និងដាក់ស្នើផែនការគ្រប់គ្រងព្រៃផ្តល់ផល ក្រៅពីព្រៃសម្បទានក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ជូនប្រធានរដ្ឋបាលព្រៃឈើដើម្បីពិនិត្យសម្រេច ។ ដំណើរការរៀបចំផែនការគ្រប់គ្រងព្រៃផ្តល់ផលក្រៅពីព្រៃសម្បទានត្រូវប្រព្រឹត្តទៅតាមលំនាំផែនការគ្រប់គ្រងព្រៃសម្បទាន ដូចមានចែងក្នុងមាត្រា ១៨ កឋាខ័ណ្ឌទី២ នៃច្បាប់នេះ ។

រូបវន្តបុគ្គល នីតិបុគ្គល ឬសហគមន៍ណាមួយអាចដាក់ពាក្យដេញថ្លៃដើម្បីទទួលបាននូវសិទ្ធិប្រមូលផល អនុផលព្រៃឈើប្រចាំឆ្នាំ នៅក្នុងដែនព្រៃផ្តល់ផលក្រៅពីព្រៃសម្បទាន ក្រោមនីតិវិធីនៃការដេញថ្លៃជាសាធារណៈ ។

នីតិវិធីសម្រាប់ការទទួលបានសិទ្ធិប្រមូលផល អនុផលព្រៃឈើប្រចាំឆ្នាំ នៅក្នុងដែនព្រៃផ្តល់ផលក្រៅពីព្រៃសម្បទាន ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

### មាត្រា ២២.-

ផ្នែកណាមួយនៃព្រៃបម្រុងទុកអចិន្ត្រៃយ៍ដែលជាតំបន់មជ្ឈដ្ឋានពិសេស ឬមានតម្លៃផ្នែកវិទ្យាសាស្ត្រ វប្បធម៌ ទេសចរណ៍ ឬជាតំបន់អភិរក្សជីវៈចម្រុះ ទឹក និងដី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវលើកសំណើជូនរាជរដ្ឋាភិបាល ដើម្បីដាក់ជាព្រៃការពារ ។

រាល់ការបង្កើត ឬការរំសាយព្រៃការពារត្រូវមានរបាយការណ៍ជូនរដ្ឋសភា និងព្រឹទ្ធសភា ។

### មាត្រា ២៣.-

រដ្ឋបាលព្រៃឈើត្រូវរៀបចំផែនការគ្រប់គ្រងព្រៃការពារនៃព្រៃបម្រុងទុកអចិន្ត្រៃយ៍ដែលសម្រេចដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

ការអនុវត្តន៍ច្បាប់ព្រៃឈើ និងគ្រប់សកម្មភាពប្រតិបត្តិក្នុងការរៀបចំគ្រប់គ្រងការពារគ្រប់ដែនព្រៃការពារនៃព្រៃបម្រុងទុកអចិន្ត្រៃយ៍ ជាសមត្ថកិច្ចរបស់រដ្ឋបាលព្រៃឈើគ្រប់ថ្នាក់ ។

## ជំពូកទី ៧

## អំពីលិខិតអនុញ្ញាត និងសិទ្ធិអំណាច

### មាត្រា ២៤.-

ផល អនុផលព្រៃឈើទាំងអស់ដែលស្ថិតនៅក្នុង និងមានប្រភពចេញពីព្រៃបម្រុងទុកអចិន្ត្រៃយ៍ ត្រូវចាត់ទុកជាសម្បត្តិរដ្ឋ លើកលែងតែសិទ្ធិលើផល អនុផលព្រៃឈើដែលត្រូវបានប្រគល់ដល់រូបវន្តបុគ្គល ឬនីតិបុគ្គលត្រឹមត្រូវតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។

រូបវន្តបុគ្គល នីតិបុគ្គល ឬសហគមន៍ ដែលមានបំណងប្រមូលផល អនុផលព្រៃឈើសម្រាប់គោលបំណងពាណិជ្ជកម្ម ត្រូវមានលិខិតអនុញ្ញាតប្រមូលផលព្រៃឈើចេញដោយរដ្ឋបាលព្រៃឈើ ។

ការប្រមូលផល អនុផលព្រៃឈើដោយសមាជិកសហគមន៍មូលដ្ឋានដែលមានបរិមាណស្មើ ឬក្រោមបរិមាណបំពេញសេចក្តីត្រូវការសម្រាប់ការរស់នៅជាប្រពៃណី ដូចមានចែងក្នុងជំពូកទី ៩ នៃច្បាប់នេះ មិនតម្រូវឱ្យមានលិខិតអនុញ្ញាតឡើយ ។

### មាត្រា ២៥.-

រាល់សកម្មភាពលើសម្បត្តិព្រៃឈើអចិន្ត្រៃយ៍ និងផល អនុផលព្រៃឈើនៅក្នុងព្រះរាជាណាចក្រកម្ពុជាតម្រូវឱ្យមានលិខិតអនុញ្ញាតសំខាន់ៗ ជាអាទិ៍ដូចខាងក្រោម :

១-លិខិតកំណត់កូតាអនុញ្ញាតឱ្យប្រមូលផល អនុផលព្រៃឈើប្រចាំឆ្នាំ

២-លិខិតអនុញ្ញាតប្រមូលផល អនុផលព្រៃឈើ ។

៣-លិខិតបើកផ្លូវដឹកជញ្ជូនផល អនុផលព្រៃឈើ ។

៤-លិខិតអនុញ្ញាតដឹកជញ្ជូនផល អនុផលព្រៃឈើ ។

៥-លិខិតអនុញ្ញាតប្រើប្រាស់ព្រៃឈើ ។

៦-ប្រកាសស្តីពីការបង្កើតមូលដ្ឋានឧស្សាហកម្មឈើ រោងចក្រអារឈើ សិប្បកម្មកែច្នៃផល អនុផលព្រៃឈើ ។

៧-លិខិតអនុញ្ញាតចូលព្រៃ ដើម្បីការងាររៀបចំព្រៃគុប ។

៨-លិខិតអនុញ្ញាតបង្កើតរោងសន្និធិលក់ចែកចាយផល អនុផលព្រៃឈើ ។

៩-លិខិតអនុញ្ញាតបង្កើតឡគ្រប់ប្រភេទ ដែលប្រើប្រាស់ផល អនុផលព្រៃឈើជាវត្ថុធាតុដើម ។

១០-លិខិតកំណត់កូតាអនុញ្ញាតឱ្យនាំចេញផល អនុផលព្រៃឈើ ។

១១-លិខិតអនុញ្ញាតនាំចេញ នាំចូលផល អនុផលព្រៃឈើ ។

១២-លិខិតអនុញ្ញាតផ្សេងទៀតស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។

លិខិតអនុញ្ញាតដូចមានចែងខាងលើ ត្រូវបានផ្តល់សិទ្ធិស្នើសុំចំពោះ :

១-ព្រៃសម្បទានិកដែលបានទទួលការឯកភាពលើផែនការប្រមូលផល អនុផលព្រៃឈើប្រចាំឆ្នាំ ដូចតម្រូវដោយកិច្ចព្រមព្រៀងព្រៃសម្បទាន ។

២-នីតិបុគ្គល ដែលបានទទួលការឯកភាពលើការប្រមូលផលក្នុងព្រៃផ្តល់ផលក្រៅពីព្រៃសម្បទាន ។

៣-សហគមន៍ដែលបានទទួលសិទ្ធិធ្វើការប្រមូលផលក្នុងព្រៃសហគមន៍លើសពីកម្រិតប្រើប្រាស់ជាប្រពៃណីក្រោមវិធានសហគមន៍ព្រៃឈើ ។

៤-បុគ្គល ឬអតិថិជន ដែលដឹកជញ្ជូនផល អនុផលព្រៃឈើចេញពីតំបន់ព្រៃប្រមូលផលឆ្ពោះទៅទិសដៅកំនត់។

៥-រូបវន្តបុគ្គល នីតិបុគ្គល សហគមន៍ ឬអតិថិជនទូទៅដែលអាចទទួលសិទ្ធិស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ។

លិខិតអនុញ្ញាតក្រោមមាត្រានេះ ត្រូវសំគាល់ដោយ :

១-ឈ្មោះអ្នកកាន់លិខិតអនុញ្ញាត ។

២-រយៈពេលសុពលភាពនៃលិខិតអនុញ្ញាត ។

៣-ទីតាំង និងព្រំប្រទល់ជាក់លាក់នៃតំបន់ប្រមូលផល អនុផលព្រៃឈើ

៤-បរិមាណផល អនុផលព្រៃឈើដែលបានអនុញ្ញាតគិតជាឯកតាកំណត់ដោយរដ្ឋបាលព្រៃឈើ ។

៥-ប្រភព និងទិសដៅនៃការដឹកជញ្ជូនផល អនុផលព្រៃឈើ ។

៦-ចំណុចផ្សេងទៀត អាស្រ័យតាមប្រភេទលិខិតអនុញ្ញាតដែលកំណត់ដោយរដ្ឋបាលព្រៃឈើ ។

លិខិតអនុញ្ញាតក្រោមមាត្រានេះអាចពន្យារពេលបន្តប្រើប្រាស់បាន ដោយផ្អែកលើរបាយការណ៍វាយតម្លៃពីរដ្ឋបាលព្រៃឈើមានសមត្ថកិច្ច ។

គំរូឯកសារជាលាយលក្ខអក្សរសម្រាប់លិខិតអនុញ្ញាតនីមួយៗ ត្រូវកំណត់ជាផ្លូវការដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា ២៦.-**

ការទទួលខុសត្រូវក្នុងការចេញលិខិតអនុញ្ញាតមានដូតទៅ :

**រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទមានសិទ្ធិអំណាចសម្រេចលើ :**

១-លិខិតកំណត់កូតាអនុញ្ញាតឱ្យប្រមូលផល អនុផលព្រៃឈើសម្រាប់ព្រៃសម្បទាន និងព្រៃផ្តល់ផលក្រៅពីព្រៃសម្បទាន ។

២-កូតាអនុញ្ញាតឱ្យនាំចេញ និងនាំចូលផល អនុផលព្រៃឈើ យោងតាមសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល ។

៣-លិខិតអនុញ្ញាតប្រើប្រាស់ព្រៃឈើ ដូចមានចែងក្នុងមាត្រា ២៧ នៃច្បាប់នេះ ។

៤-ប្រកាសស្តីពីការបង្កើតមូលដ្ឋានឧស្សាហកម្មឈើ រោងចក្រអារឈើ និងសិប្បកម្មកែច្នៃផល អនុផលព្រៃឈើប្រភេទធំ និងមធ្យម ។

**ប្រធានរដ្ឋបាលព្រៃឈើមានសិទ្ធិអំណាចផ្តល់ :**

១-លិខិតអនុញ្ញាតប្រមូលផល អនុផលព្រៃឈើសម្រាប់ព្រៃសម្បទាន និងព្រៃផ្តល់ផលក្រៅពីព្រៃសម្បទាន ។

២-លិខិតបើកផ្លូវដឹកជញ្ជូនផល អនុផលព្រៃឈើចេញពីព្រៃសម្បទាន និងព្រៃផ្តល់ផលក្រៅពីព្រៃសម្បទាន។

៣-លិខិតអនុញ្ញាតដឹកជញ្ជូនផល អនុផលព្រៃឈើ សម្រាប់នាំចេញ នាំចូល ។

៤-លិខិតអនុញ្ញាតចូលព្រៃដើម្បីដំណើរការរៀបចំព្រៃគុបមុនពេលចេញលិខិតអនុញ្ញាតប្រមូលផល អនុផលព្រៃឈើប្រចាំឆ្នាំ ។

៥-លិខិតអនុញ្ញាត ឬចុះទិដ្ឋាការលើអាជ្ញាប័ណ្ណនាំចេញនាំចូលផល អនុផលព្រៃឈើ ។

**នាយកខ័ណ្ឌរដ្ឋបាលព្រៃឈើមានសិទ្ធិអំណាចផ្តល់ :**

១-លិខិតកំណត់កូតាអនុញ្ញាតឱ្យប្រមូលផល អនុផលព្រៃឈើសម្រាប់សហគមន៍មូលដ្ឋាន ។

២-លិខិតអនុញ្ញាតឱ្យបង្កើតរោងសន្និធិលក់ចែកចាយផល អនុផលព្រៃឈើ និងសិប្បកម្មកែច្នៃផល អនុផលព្រៃឈើប្រភេទតូច ។

៣-លិខិតអនុញ្ញាតឱ្យបង្កើតឡគ្រប់ប្រភេទដែលប្រើប្រាស់ផល អនុផលព្រៃឈើជាវត្ថុធាតុដើមមានលក្ខណៈឧស្សាហកម្ម ឬសិប្បកម្ម ។

៤-លិខិតអនុញ្ញាតបើកផ្លូវដឹកជញ្ជូនផល អនុផលព្រៃឈើចេញពីព្រៃសហគមន៍ ។

**នាយផ្នែករដ្ឋបាលព្រៃឈើមានសិទ្ធិអំណាចផ្តល់ :**

១-លិខិតអនុញ្ញាតប្រមូលផល អនុផលព្រៃឈើលើបរិមាណលើសពីសិទ្ធិប្រើប្រាស់ជាប្រពៃណី សម្រាប់សហគមន៍មូលដ្ឋានក្នុងព្រៃសហគមន៍ ។

២-រាល់លិខិតអនុញ្ញាតដឹកជញ្ជូនផល អនុផលព្រៃឈើដែលមានប្រភពចេញពីតំបន់ដែនសមត្ថកិច្ចរបស់ផ្នែករដ្ឋបាលព្រៃឈើនោះ ។

**មាត្រា ២៧.-**

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទមានសិទ្ធិអំណាចចេញលិខិតអនុញ្ញាតប្រើប្រាស់ព្រៃឈើដល់រូបវន្តបុគ្គល នីតិបុគ្គល សម្រាប់ដំណើរការសកម្មភាពនៅក្នុងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ ដូចខាងក្រោម :

១-ការសិក្សាស្រាវជ្រាវបច្ចេកទេស និងវិទ្យាសាស្ត្រ ។

២-ការអប់រំ និងការបណ្តុះបណ្តាលវិស័យកសិកម្ម ។

៣-ការប្រើប្រាស់ធនធានទឹកសម្រាប់ប្រព័ន្ធស្រោចស្រព ឬគោលបំណងកសិកម្ម ដោយមានការឯកភាពពីក្រសួងធនធានទឹក និងឧតុនិយម ។

៤-ការបង្កើតសួនរុក្ខជាតិតាមសាស្ត្រ ឬស្ថានីយ៍ពិសោធន៍ ។

៥-ការបង្កើតថ្នាលកូនឈើត្រូវផ្ទេរ ។

៦-ការបង្កើតតំបន់សម្រាប់សម្រាកលំហែ ទស្សនាចរកំសាន្ត ឬការថតភាពយន្តឯកសារ ។

លិខិតអនុញ្ញាតប្រើប្រាស់ព្រៃឈើនេះមិនត្រូវយកទៅប្រើដើម្បីប្រមូលផល អនុផលព្រៃឈើពីតំបន់ដែលបានកំនត់សម្រាប់សកម្មភាពខាងលើឡើយ លើកលែងតែការដកហូតសម្រាប់គោលបំណងស្រាវជ្រាវរុក្ខវប្បកម្ម ដើម្បីបង្កើនគុណភាពព្រៃឈើ ។

## ជំពូកទី ៨

## ការហាមឃាត់ការប្រមូលផល អនុផលព្រៃឈើ និងការការពារព្រៃឈើ

**មាត្រា ២៨.-**

រាល់ការផ្តល់ ឬបែងចែកព្រៃបម្រុងទុកអចិន្ត្រៃយ៍សម្រាប់ការប្រមូលផល អនុផលព្រៃឈើ ស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះអាចប្រព្រឹត្តទៅបានតែក្នុងករណីព្រៃបម្រុងទុកអចិន្ត្រៃយ៍នោះជាប្រភេទព្រៃផ្តល់ផល និងមានសក្តានុពលផ្តល់ផលដែលការគ្រប់គ្រង និងត្រួតពិនិត្យត្រូវតែអនុវត្តក្រមបច្ចេកទេស អនុវត្តគ្រប់គ្រងព្រៃឈើកម្ពុជា ។

គ្មានបុគ្គលណាមានសិទ្ធិផ្តល់លិខិតអនុញ្ញាតប្រមូលផល អនុផលព្រៃឈើនៅក្នុងដែនព្រៃការពារគ្រប់ប្រភេទនៃព្រៃបម្រុងទុកអចិន្ត្រៃយ៍ឡើយ ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាចស្នើសុំរាជរដ្ឋាភិបាលកែប្រែដែនព្រៃការពារទៅជាដែនព្រៃផ្តល់ផល នៅពេលដែលរដ្ឋបាលព្រៃឈើបានផ្តល់ទិន្នន័យសិក្សាថ្មីចំពោះព្រៃការពារណាមួយដែលអាចមានសក្តានុពលគ្រប់គ្រាន់សំរាប់ដកហូត បើពុំនោះទេការប្រមូលផល អនុផលព្រៃឈើត្រូវហាមឃាត់ ។

**មាត្រា ២៩.-**

លើកលែងតែមានការអនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយមូលហេតុជាអាទិ៍ លក្ខខណ្ឌអាកាសធាតុមិនអំណោយផល ឈើចំណីផ្លូវដែលត្រូវសាងសង់ដោយមានការអនុញ្ញាត ឬលក្ខខណ្ឌឧបទ្ទវហេតុផ្សេងទៀត ដែលស្នើឡើងដោយរដ្ឋបាលព្រៃឈើ ការប្រមូលផល អនុផលព្រៃឈើដូចខាងក្រោមក្នុងព្រៃបម្រុងទុកអចិន្ត្រៃយ៍ ត្រូវបានហាមឃាត់ :

១-ប្រភេទឈើជាប់ក្នុងលំដាប់ថ្នាក់ ដែលមិនទាន់ដល់ទំហំអប្បបរមាអនុញ្ញាតឱ្យកាប់រំលំ ។

២-ប្រភេទឈើដែលមានដោយកម្រ ។

៣-ប្រភេទឈើដែលប្រជាជនមូលដ្ឋានចោះយកជ័រតាមប្រពៃណី ។

៤-ដើមឈើផ្តល់ជ័រមានតម្លៃ ។

ផល អនុផលព្រៃឈើដែលហាមឃាត់ដូចមានចែងក្នុងកថាខ័ណ្ឌទី១ នៃមាត្រានេះ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា ៣០.-**

ហាមឃាត់ការកែច្នៃផល អនុផលព្រៃឈើ ឬការបង្កើតនិងដំណើរការមូលដ្ឋានឧស្សាហកម្មឈើ រោងចក្រអារឈើ រោងចក្រកែច្នៃឈើ សិប្បកម្មកែច្នៃផល អនុផលព្រៃឈើ និងឡគ្រប់ប្រភេទនៅក្នុងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ ។

គ្រប់មូលដ្ឋានកែច្នៃផល អនុផលព្រៃឈើ និងឡគ្រប់ប្រភេទ ត្រូវមានទីតាំងស្ថិតនៅចំងាយប្រាំ (៥)គីឡូម៉ែត យ៉ាងតិច ពីដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទអាចធ្វើការលើកលែងការហាមឃាត់ដែលចែងក្នុងកថាខ័ណ្ឌទី២ នៃមាត្រានេះ ក្នុងករណីដែលរដ្ឋបាលព្រៃឈើសិក្សាឃើញថា ផលប្រយោជន៍នៃការលើកលែងនេះមិនមានផលប៉ះពាល់សង្គម បរិស្ថាន ឬមានផលប៉ះពាល់កម្រិតទាប ។

**មាត្រា ៣១.-**

ការឈូសឆាយដីព្រៃក្នុងគោលបំណងស្ថាបនាផ្លូវសាធារណៈ ក្នុងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ត្រូវបានហាមឃាត់ លើកលែងតែមានការសម្រេចពីរាជរដ្ឋាភិបាលតាមសំណើរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន ដោយមានការពិគ្រោះយោបល់ជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

ការឈូសឆាយដីព្រៃក្នុងគោលបំណងស្ថាបនាផ្លូវព្រៃក្នុងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ត្រូវបានហាមឃាត់ លើកលែង តែមានការសម្រេចពីក្រសួងកសិកម្ម រុក្ខាម្រាញ់ និងនេសាទតាមសំណើរបស់ប្រធានរដ្ឋបាលព្រៃឈើ ។

រាល់គំរោងស្ថាបនាផ្លូវសាធារណៈ ឬផ្លូវព្រៃក្នុងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ ត្រូវមានការពិគ្រោះយោបល់ជាមួយ អាជ្ញាធរដែនដី និងសហគមន៍មូលដ្ឋាន និងការវាយតម្លៃ ហេតុប៉ះពាល់ដល់បរិស្ថាន និងផលប៉ះពាល់ដល់សង្គម ស្រប តាមមាត្រា ៤ នៃច្បាប់នេះ ។

ការដាក់តាំងលំនៅដ្ឋានថ្មីតាមដងផ្លូវសាធារណៈ ឬផ្លូវព្រៃក្នុងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ ត្រូវបានហាមឃាត់ លើកលែងតែមានការអនុញ្ញាតពីរាជរដ្ឋាភិបាល ។

**មាត្រា ៣២.-**

ព្រៃឈើត្រូវបានការពារប្រឆាំងនឹងរាល់សកម្មភាពដែលធ្វើឱ្យខូចខាតបណ្តាលមកពីការធ្វើអាជីវកម្មហួសហេតុ ការកាប់រានដីព្រៃដោយរំលោភ ការបំពុលមជ្ឈដ្ឋានព្រៃឈើ ភ្លើងឆេះព្រៃ ការធ្វើចំការពនេរចរ ជម្ងឺ សត្វល្អិតចង្រៃ និងការនាំចូលប្រភេទរុក្ខជាតិ និងសត្វរាតត្បាត ។

សកម្មភាពដែលនាំឱ្យខូចខាតដល់ព្រៃឈើដែលត្រូវបានហាមឃាត់មានដូចជា :

១-រំកិល ដកចេញ ឬបំផ្លាញគោលសីមា ឬសញ្ញាសំគាល់សម្រាប់កំណត់ដែនព្រៃឈើ ។

២-គ្រៀវ បំពុល កាប់បំផ្លាញ ផ្តួលរំលំដើមឈើ ឬគាស់រំលីងគល់ឈើដោយគ្មានការចាំបាច់ខាងបច្ចេកទេស ។

៣-ប្រើសិទ្ធិប្រមូលផល អនុផលព្រៃឈើខុសពីសិទ្ធិ ដែលត្រូវបានទទួលស្គាល់ ឬអនុញ្ញាត ។

៤-ប្រើប្រាស់មធ្យោបាយផ្សេងៗ លែង ឬចងសត្វពាហនៈក្នុងកន្លែងដែលមានកូនឈើដុះថ្មីក្រោយពេលអាជីវកម្ម ឬភ្លើងព្រៃ ឬក្នុងតំបន់ព្រៃកំពុងតែដាំ ឬទើប នឹងដាំ ។

៥-បង្កើតមូលដ្ឋានកែច្នៃវល្លិរមៀត ឬអនុផលព្រៃឈើផ្សេងទៀតដែលនាំមកនូវការបំពុល ឬបំផ្លាញមជ្ឈដ្ឋានព្រៃឈើ ។

**មាត្រា ៣៣.-**

រាល់សកម្មភាពកាប់រានដីព្រៃក្នុងព្រៃបម្រុងទុកអចិន្ត្រៃយ៍ត្រូវបានហាមឃាត់ លើកលែងតែករណីដែលមានចែងក្នុងមាត្រា ៣១ មាត្រា ៣៥ និងមាត្រា ៣៧ នៃច្បាប់នេះ ។

**មាត្រា ៣៤.-**

ការនាំចេញ នាំចូលគ្រាប់ពូជរុក្ខជាតិព្រៃ ឬប្រភេទរុក្ខជាតិព្រៃត្រូវឆ្លងកាត់ការសិក្សាស្រាវជ្រាវ វាយតម្លៃពីរដ្ឋបាលព្រៃឈើ និងត្រូវមានការអនុញ្ញាតពីរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

ការនាំចូលគ្រាប់ពូជរុក្ខជាតិព្រៃគ្រប់ប្រភេទ ត្រូវមានទិដ្ឋាការគ្រាប់ពូជ ដែលបញ្ជាក់ដោយអាជ្ញាធរវិទ្យាសាស្ត្ររបស់ប្រទេសនាំចេញ ។

**មាត្រា ៣៥.-**

បន្ថែមលើច្បាប់ដទៃទៀតដែលពាក់ព័ន្ធនឹងការយកថ្ម ដី ខ្សាច់ រ៉ែ និងធនធានធម្មជាតិដទៃទៀត ដែលត្រូវអនុវត្តក្នុងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ ត្រូវមានការសិក្សាវាយតម្លៃជាមុនពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងទទួលការអនុញ្ញាតពីរាជរដ្ឋាភិបាលដោយត្រូវអនុវត្តតាមមាត្រា ៤ នៃច្បាប់នេះ ។

ការអនុញ្ញាតនេះត្រូវកម្រិតផងដែរនូវវិធានការការពារ និងស្តារឡើងវិញនៅទីកន្លែងគាស់កកាយយកថ្ម ដី ខ្សាច់ រ៉ែ និងធនធានធម្មជាតិដទៃទៀត ដែលអ្នកទទួលសិទ្ធិត្រូវទទួលបន្ទុកដើម្បី :

១-ចៀសវាងបង្ក ឬធ្វើអោយធ្ងន់ធ្ងរដល់ការហូរច្រោះបាក់ដី ឬធ្វើឱ្យខូចខាតដល់ការលូតលាស់របស់រុក្ខជាតិ ឬធ្វើឱ្យខូចខាតដល់ប្រព័ន្ធជលសាស្ត្រ និងគុណភាពទឹក ។

២-រៀបចំស្តារទីតាំងនោះឱ្យមានសភាពដូចដើមវិញ ក្រោយពេលបញ្ចប់កិច្ចការគាស់កកាយយកថ្ម ដី ខ្សាច់ រ៉ែ និងធនធានធម្មជាតិដទៃទៀតក្នុងរយៈពេល ដែលលិខិតអនុញ្ញាតបានកំណត់ ។

**មាត្រា ៣៦.-**

ហាមបង្កភ្លើងឆេះព្រៃក្នុងដែនសម្បត្តិព្រៃឈើអចិន្ត្រៃយ៍ ។ ការប្រើប្រាស់ភ្លើងអាចអនុគ្រោះចំពោះរដ្ឋបាលព្រៃឈើ ដើម្បីផលប្រយោជន៍រុក្ខវប្បកម្ម ឬអនាម័យព្រៃ ។

គោលការណ៍ណែនាំក្នុងការកំណត់តំបន់ត្រួតពិនិត្យភ្លើងឆេះព្រៃ ការការពារភ្លើងឆេះព្រៃ និងការបង្កើតគណៈកម្មាធិការប្រយុទ្ធនឹងភ្លើងឆេះព្រៃ សម្រាប់ជាវិធានការអនុវត្តគ្រប់តំបន់ព្រៃឈើ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

ប្រជាពលរដ្ឋ កងកម្លាំងប្រដាប់អាវុធ និងអាជ្ញាធរដែនដីគ្រប់ថ្នាក់ ត្រូវមានករណីយកិច្ចទទួលខុសត្រូវ ថែរក្សាការពារព្រៃឈើ បង្ការ និងប្រយុទ្ធនឹងភ្លើងព្រៃ ។

**មាត្រា ៣៧.-**

សហគមន៍មូលដ្ឋានដែលប្រកបរបរចំការពនេចរមានលក្ខណៈប្រពៃណី អាចអនុវត្តលើដីកម្មសិទ្ធិសហគមន៍ជនជាតិដើមភាគតិច ដែលបានចុះបញ្ជិការរួចហើយជាមួយរដ្ឋ ។ ផ្នែករដ្ឋបាលព្រៃឈើនៃមូលដ្ឋាននេះ ត្រូវផ្តល់ការអនុញ្ញាតការគ្រប់គ្រង និងការត្រួតពិនិត្យនៃសកម្មភាពនេះ ដែលជាផ្នែកមួយនៃផែនការគ្រប់គ្រងព្រៃសហគមន៍នោះ ។ ការអនុវត្តន៍ចំការពនេចរ ត្រូវហាមឃាត់ចំពោះព្រៃធម្មជាតិមិនទាន់ប៉ះពាល់ក្នុងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ ។

ដីព្រៃឈើដែលរៀបចំបម្រុងសម្រាប់ចំការពនេចរ ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៣៨.-**

ការអារច្រៀក និងការចាំងឈើមូលនៅក្នុងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ ត្រូវបានហាមឃាត់ ។

ការប្រើប្រាស់រណារយន្តជាមធ្យោបាយប្រមូលផលព្រៃឈើនៅក្នុងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ត្រូវបានហាមឃាត់ លើកលែងតែមានលិខិតអនុញ្ញាតប្រើប្រាស់ចេញដោយរដ្ឋបាលព្រៃឈើ ។

**មាត្រា ៣៩.-**

គ្មានរូបវន្តបុគ្គល ឬនីតិបុគ្គលណាមួយមានសិទ្ធិផ្តល់ការអនុញ្ញាត ទោះដោយផ្ទាល់ក្តី ឬដោយប្រយោលក្តី ឱ្យកាប់ដើម ឈើ រានដីព្រៃឈើ ឬធ្វើសកម្មភាពគ្រប់យ៉ាងដើម្បីប្រមូលផល អនុផលព្រៃឈើ ឬកាន់កាប់ដីក្នុងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ផ្ទុយនឹងបទប្បញ្ញត្តិនៃច្បាប់នេះឡើយ ។

## ជំពូកទី ៩
## សិទ្ធិប្រើប្រាស់ជាប្រពៃណី ការគ្រប់គ្រងព្រៃសហគមន៍ និងព្រៃឯកជន

### មាត្រា ៤០.-

ចំពោះសហគមន៍មូលដ្ឋានរស់នៅក្នុង ឬក្បែរដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ រដ្ឋត្រូវទទួលស្គាល់ និងធានាសិទ្ធិប្រើប្រាស់ជាប្រពៃណីរបស់សហគមន៍មូលដ្ឋាននោះសម្រាប់គោលបំណងទំនៀមទំលាប់ ជំនឿ សាសនា និងការរស់នៅ ដូចមានចែងក្នុងមាត្រានេះ ។

សិទ្ធិប្រើប្រាស់ជាប្រពៃណីលើផល អនុផលព្រៃឈើដោយសហគមន៍មូលដ្ឋានមិនតម្រូវឱ្យមានលិខិតអនុញ្ញាតប្រមូលផលឡើយ ។ សិទ្ធិប្រើប្រាស់ជាប្រពៃណីក្រោមមាត្រានេះរួចមាន :

១-ការរើសប្រមូលឈើងាប់ ការបេះផ្លែឈើព្រៃ ការរុករកឃ្មុំ ការចោះយកជ័រ និងរុករកអនុផលព្រៃឈើដទៃទៀតទាំងអស់ ។

២-ការប្រើប្រាស់ឈើមកសង់លំនៅដ្ឋាន ក្រោលសត្វ របង និងសម្រាប់ធ្វើឧបករណ៍កសិកម្ម ។

៣-ការច្រូតយកស្មៅ ឬលែងសត្វពាហនៈឱ្យស៊ីស្មៅក្នុងព្រៃ ។

៤-ការប្រើប្រាស់ផល អនុផលព្រៃឈើផ្សេងទៀតស្របតាមការប្រើប្រាស់ជាប្រពៃណី ជាលក្ខណៈគ្រួសារ ។

៥-សិទ្ធិដោះដូរ ឬលក់អនុផលព្រៃឈើដោយពុំចាំបាច់មានលិខិតអនុញ្ញាត ប្រសិនបើការលក់ដូរនេះមិនគំរាមកំហែងដល់និរន្តរភាពនៃព្រៃឈើ ។ អតិថិជន ឬភាគីទីបីណាមួយដែលបានប្រមូលទិញអនុផលព្រៃឈើទាំងនោះពីសហគមន៍មូលដ្ឋានក្នុងគោលដៅពាណិជ្ជកម្មស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ អាចធ្វើការដឹកជញ្ជូនទៅកាន់ទិសដៅបានដោយតម្រូវឱ្យមានលិខិតអនុញ្ញាតដឹកជញ្ជូន ក្រោយពេលបានបង់ថ្លៃសួយសារ និងបុព្វលាភលើអនុផលព្រៃឈើទាំងនោះរួច ។

សហគមន៍មូលដ្ឋានមិនអាចផ្ទេរសិទ្ធិប្រើប្រាស់ប្រពៃណីឱ្យទៅភាគីទីបីបានឡើយ ទោះបីជាមានកិច្ចព្រមព្រៀងទៅវិញទៅមកក្តី ឬស្ថិតក្រោមកិច្ចសន្យាក្តី ។ សិទ្ធិប្រើប្រាស់នៃប្រពៃណីត្រូវ :

១-ស្របតាមលំនឹងធម្មជាតិ មាននិរន្តរភាពចំពោះធនធានព្រៃឈើ និងគោរពសិទ្ធិអ្នកដទៃ ។

២-ស្របតាមការអនុញ្ញាត និងការហាមឃាត់ ដែលកំណត់ដោយបទប្បញ្ញត្តិនៃច្បាប់នេះ ។

### មាត្រា ៤១.-

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទមានសិទ្ធិប្រគល់ផ្នែកណាមួយនៃព្រៃបម្រុងទុកអចិន្ត្រៃយ៍ឱ្យទៅសហគមន៍ដែលរស់នៅក្នុង ឬជិតតំបន់ព្រៃឈើ ក្រោមរូបភាពជាព្រៃសហគមន៍ ។

### មាត្រា ៤២.-

ខ័ណ្ឌរដ្ឋបាលព្រៃឈើ តាមរយៈដំណើរការពិគ្រោះយោបល់ជាមួយសមត្ថកិច្ចពាក់ព័ន្ធដទៃទៀត មានភារកិច្ចសិក្សារៀបចំព្រៃបម្រុងទុកអចិន្ត្រៃយ៍ ដើម្បីបង្កើតជាព្រៃសហគមន៍ដោយកំណត់ព្រំប្រទល់ច្បាស់លាស់ និងមានទំហំសមស្របផ្អែក តាមលទ្ធភាពធនធានព្រៃឈើ និងតម្រូវការប្រើប្រាស់ជាប្រពៃណីរបស់សហគមន៍ ។

នាយខ័ណ្ឌរដ្ឋបាលព្រៃឈើមានសិទ្ធិសម្រេចចុះកិច្ចព្រមព្រៀងព្រៃសហគមន៍ជាមួយសហគមន៍មូលដ្ឋានណាមួយដែលរស់នៅក្នុង ឬក្បែរដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ ។ កិច្ចព្រមព្រៀងនេះ ត្រូវមានសុពលភាពមិនលើសពីរយៈពេលដប់ប្រាំ (១៥) ឆ្នាំ តែអាចពន្យារបានដោយផ្អែកលើរបាយការណ៍ពិនិត្យ និងវាយតម្លៃឡើងវិញរបស់ថ្នាក់ផ្នែករដ្ឋបាលព្រៃឈើ ។

**មាត្រា ៤៣.-**

ព្រៃសហគមន៍ត្រូវបានគ្រប់គ្រងក្នុងលក្ខណៈសេដ្ឋកិច្ច និងដោយធានានិរន្តរភាពដោយសហគមន៍មូលដ្ឋាន ស្របតាមផែនការគ្រប់គ្រងព្រៃសហគមន៍ វិធានសហគមន៍ព្រៃឈើ និងគោលការណ៍ណែនាំអំពីសហគមន៍ព្រៃឈើ ។ រដ្ឋបាលព្រៃឈើត្រូវផ្តល់ជំនួយបច្ចេកទេសតាមការស្នើសុំរបស់សហគមន៍មូលដ្ឋាន និងត្រូវតាមដានត្រួតពិនិត្យការអនុវត្តន៍ផែនការគ្រប់គ្រងព្រៃសហគមន៍ ។

ផែនការគ្រប់គ្រងព្រៃសហគមន៍ត្រូវរៀបចំដោយសហគមន៍មូលដ្ឋាន និងមានការយល់ព្រមដោយថ្នាក់ខ័ណ្ឌរដ្ឋបាលព្រៃឈើ ។ ផែនការនេះនឹងត្រូវផ្ញើជូនទៅថ្នាក់កណ្តាលរដ្ឋបាលព្រៃឈើ និងត្រូវពិនិត្យឡើងវិញជារៀងរាល់ប្រាំ (៥) ឆ្នាំម្តង ឬមុនពេលកំណត់ក្នុងករណីចាំបាច់ ។

ទោះបីព្រៃសហគមន៍ត្រូវបានដាំដុះ ឬដុះដោយធម្មជាតិក៏ដោយ ក៏ការគ្រប់គ្រងត្រូវអនុវត្តតាមផែនការគ្រប់គ្រងព្រៃសហគមន៍ និងក្រោមការឧបត្ថម្ភបច្ចេកទេស និងត្រួតពិនិត្យបច្ចេកទេសដោយរដ្ឋបាលព្រៃឈើ ។

វិធានសម្រាប់ការបង្កើត ការគ្រប់គ្រង និងការប្រើប្រាស់ព្រៃសហគមន៍ ត្រូវកំណត់ដោយអនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍ព្រៃឈើ ។

គោលការណ៍ណែនាំអំពីសហគមន៍ព្រៃឈើត្រូវកំណត់ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា ៤៤.-**

សហគមន៍មូលដ្ឋានដែលដំណើរការក្រោមកិច្ចព្រមព្រៀងព្រៃសហគមន៍ មានសិទ្ធិប្រមូលផល អនុផលព្រៃឈើនៅក្នុងដែនព្រៃឈើស្របតាមផែនការគ្រប់គ្រងព្រៃសហគមន៍ដែលបានកំណត់ព្រំប្រទល់ជូន ដូចមានចែងក្នុងកិច្ចព្រមព្រៀងព្រៃសហគមន៍ ។

សហគមន៍មូលដ្ឋានមិនអាចយកព្រៃសហគមន៍ទៅប្រើប្រាស់ក្រោមរូបភាពជាព្រៃសម្បទាន ឬលក់ ដូរ ផ្ទេរសិទ្ធិលើព្រៃឈើនោះឱ្យភាគីទីបីបានឡើយ ។

**មាត្រា ៤៥.-**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទត្រូវទទួលស្គាល់ព្រៃពាក់ព័ន្ធជំនឿសាសនារបស់សហគមន៍មូលដ្ឋានដែលរស់នៅក្នុង ឬក្បែរព្រៃនោះទុកជាព្រៃការពារសម្រាប់គោលបំណងសាសនា វប្បធម៌ ឬការអភិរក្ស ។ ដើមឈើជំនឿសាសនាអាចត្រូវបានដៅសម្គាល់ជាពិសេសមិនអនុញ្ញាតឱ្យកាប់រំលំ និងត្រូវកំណត់ក្នុងផែនការគ្រប់គ្រងព្រៃសហគមន៍ ។

**មាត្រា ៤៦.-**

បុគ្គលដែលបានដាំដើមឈើលើដីកម្មសិទ្ធិឯកជនផ្ទាល់ ឬលើដីព្រៃរបស់រដ្ឋដែលបានប្រគល់សិទ្ធិប្រើប្រាស់ មានសិទ្ធិថែរក្សា អភិវឌ្ឍ ប្រើប្រាស់ លក់ និងចែកចាយផលិតផលរបស់ខ្លួនបាន ។

វិធានស្តីពីព្រៃឈើឯកជន ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីជំរុញលើកទឹកចិត្ត ដល់បុគ្គល ក្នុងការដាំដុះ និងថែរក្សាចំការព្រៃឈើ ។

**មាត្រា ៤៧.-**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទអាចផ្តល់ជូនបុគ្គល និងសហគមន៍ដែលអនុវត្តការគ្រប់គ្រងព្រៃឈើ ឬដាំដើមឈើដែលសម្រេចបាននូវបរិមាណ និងគុណភាពខ្ពស់ នូវប្រព័ន្ធលើកទឹកចិត្តទៅតាមវិធានមានជាអាទិ៍ :

១-ប្រគល់លិខិតសរសើរ ប័ណ្ណសរសើរ និងប្រគល់គ្រឿងឥស្សរិយយស ។

២-ផ្តល់ជំនួយអភិវឌ្ឍន៍ដោយផ្ទាល់ក្រោមកិច្ចសហប្រតិបត្តិការអន្តរជាតិ ។

៣-ពន្យាររយៈពេលកិច្ចព្រមព្រៀងសំរាប់ព្រៃសហគមន៍ ។

៤-ផ្សព្វផ្សាយពីសកម្មភាពមានស្នាដៃ ។

## ជំពូកទី ១០

## ការអភិរក្សសត្វព្រៃ

**មាត្រា ៤៨.-**

ពពួកសត្វព្រៃគ្រប់ប្រភេទនៅក្នុងព្រះរាជាណាចក្រកម្ពុជាគឺជាសម្បត្តិរបស់រដ្ឋ និងជាសមាសភាគនៃធនធានព្រៃឈើដែលរួមមាន : ពួកថនិកសត្វ បក្សីសត្វ ឧរង្គសត្វ ថលជលិកសត្វ បាណកសត្វ និងសត្វឥតឆ្អឹងកងផ្សេងទៀតព្រមទាំងពង កូនរបស់វា ។ ពពួកសត្វព្រៃទាំងអស់នេះស្ថិតនៅក្រោមការគ្រប់គ្រងសិក្សាស្រាវជ្រាវ និងការអភិរក្សដោយរដ្ឋបាលព្រៃឈើ ដោយមិនរាប់បញ្ចូលត្រី និងសត្វបង្កកំណើតក្នុងទឹក ។

សំណាកសត្វព្រៃ គឺជាសត្វព្រៃដែលស្លាប់ ទោះជានៅខ្លួនទាំងមូល សរីរាង្គក្នុង សរីរាង្គក្រៅ បំណែកឆ្អឹង ឬផលិតផលកែច្នៃ ត្រូវស្ថិតក្រោមសិទ្ធិគ្រប់គ្រងរបស់រដ្ឋបាលព្រៃឈើ ។

គ្រប់ប្រភេទសត្វព្រៃទាំងអស់ ត្រូវបានបែងចែកជាបីក្រុម គឺ :

១-ក្រុមប្រភេទជិតផុតពូជ

២-ក្រុមប្រភេទមានដោយកម្រ

៣-ក្រុមប្រភេទមានដោយបង្គួរ ។

លក្ខណៈវិនិច្ឆ័យសម្រាប់ចាត់ថ្នាក់ក្រុមនីមួយៗ និងបញ្ជីឈ្មោះប្រភេទសត្វក្នុងក្រុមប្រភេទជិតផុតពូជ និងប្រភេទមានដោយកម្រដែលអាចប្រែប្រួលទៅតាមតំបន់ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទតាមសំណើរបស់រដ្ឋបាលព្រៃឈើ ដោយមានការពិគ្រោះយោបល់ជាមួយក្រសួងបរិស្ថាន ។

**មាត្រា ៤៩.-**

ហាមឃាត់ដាច់ខាតរាល់សកម្មភាពបរបាញ់ យាយីបំផ្លិចបំផ្លាញសត្វព្រៃគ្រប់ប្រភេទដោយ :

១-ការប្រើប្រាស់មធ្យោបាយបង្កគ្រោះថ្នាក់គ្រប់ប្រភេទ ។

២-ការប្រមាញ់ក្នុងរដូវកាលហាមឃាត់ ។

៣-ការប្រមាញ់ក្នុងតំបន់ការពារ និងទីសាធារណៈពិសេស ។

ដោយមានការឯកភាពពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋបាលព្រៃឈើមានសិទ្ធិចេញលិខិតអនុញ្ញាតចំពោះប្រភេទសត្វក្នុងក្រុមប្រភេទជិតផុតពូជ និងក្រុមប្រភេទមានដោយកម្រ សម្រាប់គោលបំណងដូចខាងក្រោម :

១-ការសិក្សាអប់រំ ឬការស្រាវជ្រាវិទ្យាសាស្ត្រ ។

២-ការគាំទ្រដល់កម្មវិធីនៃការចាប់បង្កាត់ពូជ ។

៣-ការផ្លាស់ប្តូរប្រភេទសត្វ អនុលោមតាមកិច្ចព្រមព្រៀងសហប្រតិបត្តិការអន្តរជាតិ ។

រាល់ការធ្វើសកម្មភាពដូចខាងក្រោម ចំពោះប្រភេទសត្វក្នុងក្រុមប្រភេទជិតផុតពូជ និងក្រុមប្រភេទមានដោយកម្រ ត្រូវហាមឃាត់ :

១-ការយាយី ឬបំផ្លិចបំផ្លាញដល់ប្រភេទសត្វខាងលើ និងជម្រករបស់ប្រភេទសត្វទាំងនេះ ។

២-ការបរបាញ់ ទាក់ចាប់ ដាក់អង្គុប បំពុល ។

៣-ការយកធ្វើជាកម្មសិទ្ធិ សន្និធិ ឬថែរក្សាជាលក្ខណៈសួនសត្វ ឬគ្រួសារ ។

៤-ការដឹកជញ្ជូន ។

៥-ការធ្វើពាណិជ្ជកម្ម ។

៦-ការនាំចេញ នាំចូល ។

វិធានការនៃការធ្វើសកម្មភាពចំពោះសត្វព្រៃគ្រប់ប្រភេទ ត្រូវកំណត់ដោយប្រកាសរួមរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងបរិស្ថាន ។

**មាត្រា ៥០.-**

រាល់ការធ្វើសកម្មភាពដូចខាងក្រោម ចំពោះប្រភេទសត្វក្នុងក្រុមប្រភេទមានដោយបង្គួរ ត្រូវហាមឃាត់លើកលែងតែមានលិខិតអនុញ្ញាតចេញដោយរដ្ឋបាលព្រៃឈើ ។

១-ការធ្វើសន្និធិ ការថែរក្សាជាលក្ខណៈសួនសត្វ ឬគ្រួសារ ។

២-ការដឹកជញ្ជូន និងធ្វើពាណិជ្ជកម្មលើសពីបរិមាណចាំបាច់សម្រាប់ការប្រើប្រាស់ជាប្រពៃណី ។

ការនាំចេញ នាំចូលប្រភេទសត្វព្រៃក្នុងក្រុមប្រភេទមានដោយបង្គួរ ត្រូវមានលិខិតអនុញ្ញាត ចេញដោយរដ្ឋបាលព្រៃឈើដោយមានការឯកភាពពីក្រសួងកសិកម្ម រុក្ខប្រមាញ់ និងនេសាទ ។

**មាត្រា ៥១.-**

រដ្ឋបាលព្រៃឈើត្រូវប្រមូលប្រាក់ចំណូលអភិរក្សសត្វព្រៃ និងប្រាក់សួយសារសត្វព្រៃដូចខាងក្រោម :

១-ប្រាក់ចំណូលអភិរក្សសត្វព្រៃត្រូវបង់ចូលមូលនិធិអភិវឌ្ឍន៍ព្រៃឈើជាតិ ។

២-ប្រាក់សួយសារសត្វព្រៃត្រូវបង់ចូលថវិកាជាតិ ។

ប្រាក់ចំណូលអភិរក្សសត្វព្រៃ និងប្រាក់សួយសារសត្វព្រៃត្រូវកំណត់ដោយប្រកាសរួមរវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ជំពូកទី ១១

## ថ្លៃសួយសារ និងបុព្វលាភ លើផល អនុផលព្រៃឈើ

### មាត្រា ៥២.-

លើកលែងតែករណីដូចមានចែងក្នុងមាត្រា ៥៣ នៃច្បាប់នេះ រូបវន្តបុគ្គល ឬនីតិបុគ្គលដែលប្រមូលផល អនុផលព្រៃឈើសម្រាប់គោលដៅពាណិជ្ជកម្មលើព្រៃឈើបម្រុងទុកអចិន្ត្រៃយ៍ ត្រូវបង់ថ្លៃសួយសារ និងបុព្វលាភចូលថវិកាជាតិតាមរយៈរដ្ឋបាលព្រៃឈើ ។ រាជរដ្ឋាភិបាលត្រូវកំណត់ថ្លៃសួយសារ និងបុព្វលាភ ផ្អែកតាមសំណើរួមរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

រដ្ឋមិនតម្រូវឱ្យបង់ថ្លៃសួយសារ និងបុព្វលាភ សម្រាប់ការប្រមូលផល អនុផលព្រៃឈើលើព្រៃឯកជនឡើយ ។

គំរូកិច្ចព្រមព្រៀងព្រៃសម្បទាន ត្រូវបញ្ចូលនូវតារាងនៃថ្លៃសួយសារ និងបុព្វលាភលើផល អនុផលព្រៃឈើ ។

### មាត្រា ៥៣.-

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទអាចបន្ថយ ឬមិនយកថ្លៃសួយសារ និងបុព្វលាភលើផល អនុផលព្រៃឈើ ដែលប្រមូលពីព្រៃឈើរដ្ឋសម្រាប់គោលបំណងវិទ្យាសាស្ត្រ ឬដើម្បីបង្កើនការលើកទឹកចិត្តសេដ្ឋកិច្ច ចំពោះការប្រើប្រាស់អស់លទ្ធភាពលើផលិតផល ។

រដ្ឋមិនយកថ្លៃសួយសារ និងបុព្វលាភពីសហគមន៍មូលដ្ឋានលើផល អនុផលព្រៃឈើដែលប្រមូលដោយសហគមន៍មូលដ្ឋានសម្រាប់សិទ្ធិប្រើប្រាស់ជាប្រពៃណី ឬប្រមូលពីព្រៃសហគមន៍ក្រោមកិច្ចព្រមព្រៀងសហគមន៍ឡើយ ។

### មាត្រា ៥៤.-

រាល់ផល អនុផលព្រៃឈើត្រូវវាយតម្លៃដោយមន្ត្រីរដ្ឋបាលព្រៃឈើលើបរិមាណ និងគុណភាពនៅគំនរក្នុងព្រៃគុបប្រចាំឆ្នាំ មុនពេលដឹកចេញពីព្រៃ ។

គុណភាព និងបរិមាណនៃផល អនុផលព្រៃឈើដែលបានវាយតម្លៃរួច ត្រូវចុះក្នុងកំណត់ហេតុបញ្ជីសៀវភៅ ករ ដោយមានការឯកភាពពីប្រធានរដ្ឋបាលព្រៃឈើ ។

### មាត្រា ៥៥.-

រាល់ផល អនុផលព្រៃឈើដែលបានចុះក្នុងកំណត់ហេតុបញ្ជីសៀវភៅ ករ ត្រូវបង់ប្រាក់ថ្លៃសួយសារ និងបុព្វលាភ ។

វិធាននៃការបង់ និងទទួលប្រាក់ចំណូលពីថ្លៃសួយសារផល អនុផលព្រៃឈើ ត្រូវកំណត់ដោយប្រកាសរួមរវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ៥៦.-**

អ្នកកាន់កាប់លិខិតអនុញ្ញាតប្រមូលផល អនុផលព្រៃឈើមិនអាចផ្ទេរ ឬលក់សិទ្ធិលើផល អនុផលព្រៃឈើទៅឱ្យបុគ្គលណាមួយផ្សេងទៀតបានឡើយ លុះត្រាតែខ្លួនបានបង់ថ្លៃសួយសារ និងបុព្វលាភលើផល អនុផលព្រៃឈើនោះរួច ។

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បន្ទាប់ពីមានការពិគ្រោះយោបល់ជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចសម្រេចឱ្យមានការពន្យារពេលការបង់ថ្លៃសួយសារ និងបុព្វលាភលើផល អនុផលព្រៃឈើចំពោះអ្នកកាន់កាប់លិខិតអនុញ្ញាតដែលបានទទួលស្គាល់ដោយរដ្ឋបាលព្រៃឈើ ថាបានអនុវត្តការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព ។ ការពន្យារនោះត្រូវផ្អែកតាមវិធាន និងគោលការណ៍ណែនាំស្របតាមមាត្រា ៥៥ កថាខ័ណ្ឌទី ២ នៃច្បាប់នេះ ។

**មាត្រា ៥៧.-**

ប្រសិនបើអ្នកកាន់កាប់លិខិតអនុញ្ញាតមិនបានបង់ថ្លៃសួយសារ និងបុព្វលាភតាមកម្មវិធី ពេលវេលាកំណត់ទេនោះ រដ្ឋបាលព្រៃឈើមានសិទ្ធិដកហូតយកផល អនុផលព្រៃឈើទាំងនោះដោយគ្មានលក្ខខណ្ឌ និងឃាត់ទុកផល អនុផលព្រៃឈើ ទាំងនោះរក្សាជាកម្មសិទ្ធិរបស់រដ្ឋដដែល រហូតដល់មានដំណោះស្រាយវិវាទនេះតាមផ្លូវច្បាប់ ។

**មាត្រា ៥៨.-**

មុនពេលចេញលិខិតអនុញ្ញាតប្រមូលផល អនុផលព្រៃឈើ អ្នកស្នើសុំលិខិតអនុញ្ញាតនោះត្រូវបង់ប្រាក់តំកល់ដើម្បីធានាការបង់ថ្លៃសួយសារ និងបុព្វលាភចូលថវិកាជាតិ ។ បរិមាណប្រាក់តំកល់ត្រូវកំណត់ក្នុងកិច្ចព្រមព្រៀងព្រៃសម្បទាន ឬក្នុងលិខិតកំណត់កូតាអនុញ្ញាតឱ្យប្រមូលផល អនុផលព្រៃឈើប្រចាំឆ្នាំ ។

ការប្រមូលផល អនុផលព្រៃឈើលើព្រៃសហគមន៍ក្រោមកិច្ចព្រមព្រៀងព្រៃសហគមន៍ មិនតម្រូវឱ្យមានការបង់ប្រាក់តំកល់នោះឡើយ ។

## ជំពូកទី ១២

## ការដាំដើមឈើឡើងវិញ និងមូលនិធិអភិវឌ្ឍន៍ព្រៃឈើជាតិ

**មាត្រា ៥៩.-**

ប្រជាពលរដ្ឋ កងកម្លាំងប្រដាប់អាវុធ និងអាជ្ញាធរដែនដីគ្រប់ថ្នាក់មានករណីយកិច្ចចូលរួមដាំដើមឈើ និងដាំដើមឈើឡើងវិញ ។

ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការដាំដើមឈើ និងដាំដើមឈើឡើងវិញ ត្រូវបានលើកទឹកចិត្តដោយរាជរដ្ឋាភិបាល តាមរយៈចលនារបស់សហគមន៍ និងអង្គការសង្គមផ្សេងៗទៀត ។

រដ្ឋបាលព្រៃឈើត្រូវមានវិធានការសមស្របក្នុងការអភិវឌ្ឍន៍ព្រៃឈើតាមរយៈការផ្សព្វផ្សាយ ការអប់រំ ការបំផុសដល់បុគ្គលសហគមន៍ និងមហាជនឱ្យដាំដើមឈើ និងការពារព្រៃឈើ ដោយផ្តល់នូវជំនួយការបច្ចេកទេសចាំបាច់ ។

**មាត្រា ៦០.-**

ដើម្បីជំរុញការអប់រំប្រជាពលរដ្ឋឱ្យយល់ពីសារៈសំខាន់ និងផលប្រយោជន៍នៃព្រៃឈើ ទិវាពលកម្មដាំដើមឈើជា

ប្រពៃណីជាតិ ហៅថា **វុក្ខទិវា** ត្រូវប្រារព្ធធ្វើឡើងនៅថ្ងៃទី ៩ ខែ កក្កដា ជារៀងរាល់ឆ្នាំ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ឬព្រះរាជតំណាង ។

ប្រជាពលរដ្ឋទាំងពីរភេទដែលជាគូស្រករថ្មី ត្រូវបានលើកទឹកចិត្តដាំដើមឈើពីរដើមក្រោមកិច្ចសម្របសម្រួល និងផ្តល់កូនឈើដោយមន្ត្រីរដ្ឋបាលព្រៃឈើមានសមត្ថកិច្ច ។

រាជរដ្ឋាភិបាលត្រូវកំណត់សួនសម្រាប់ជូនថ្នាក់ដឹកនាំជាន់ខ្ពស់ជាតិ និងអន្តរជាតិដាំដើមឈើដើម្បីទុកជាអនុស្សាវ-រីយ៍ ។

**មាត្រា ៦១.-**

ការដាំដើមឈើនៅលើដីព្រៃរបស់រដ្ឋ អាចធ្វើឡើងដោយរដ្ឋបាលព្រៃឈើផ្ទាល់ សហគមន៍ព្រៃឈើ ឬដោយមានការចូលរួមពីប្រជាពលរដ្ឋតាមរយៈការផ្តល់សិទ្ធិប្រើប្រាស់ដីព្រៃរបស់រដ្ឋ ។

ការដាំដើមឈើនៅលើដីកម្មសិទ្ធិឯកជនអាចធ្វើឡើងបាន ដោយសិទ្ធិវន្តស្របតាមវិធានព្រៃឯកជន ដូចមានចែងក្នុងមាត្រា ៤៦ នៃច្បាប់នេះ ។

វិធាននៃការផ្តល់សិទ្ធិប្រើប្រាស់ដីព្រៃរបស់រដ្ឋសំរាប់ការដាំឈើ ត្រូវកំណត់ដោយអនុក្រឹត្យ ។ វិធាន និងបទបញ្ញាទំងនេះត្រូវគិតពីសក្តានុពល ហេតុប៉ះពាល់បរិស្ថាន និងផលប៉ះពាល់សង្គមនៃប្រភេទឈើ ដែលត្រូវជ្រើសរើសសំរាប់ការដាំនោះ ។

**មាត្រា ៦២.-**

រាជរដ្ឋាភិបាលត្រូវបង្កើតមូលនិធិមួយហៅថា **មូលនិធិអភិវឌ្ឍន៍ព្រៃឈើជាតិ** គ្រប់គ្រត់ចាត់ចែង និងទទួលខុសត្រូវដោយគណៈកម្មាធិការអភិវឌ្ឍន៍ព្រៃឈើជាតិដែលមានរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុជាសហប្រធាន ។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការអភិវឌ្ឍន៍ព្រៃឈើជាតិត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៦៣.-**

មូលនិធិអភិវឌ្ឍន៍ព្រៃឈើជាតិមានប្រភពចំណូលមកពី :

១-វិភាគទានផ្សេងៗរបស់រាជរដ្ឋាភិបាល ។

២-បុព្វលាភលើផល អនុផលព្រៃឈើ ។

៣-ប្រាក់ចំណូលអភិរក្សសត្វព្រៃ ។

៤-ជំនួយរបស់អង្គការអន្តរជាតិនានា ។

៥-អំណោយពីសប្បុរជន និងអង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិ ។

៦-កំរៃសេវាផ្សេងៗ ពីវិស័យព្រៃឈើ ។

រាល់ចំណូលខាងលើ ត្រូវបញ្ចូលក្នុងគណនីមូលនិធិអភិវឌ្ឍន៍ព្រៃឈើជាតិ ។

**មាត្រា ៦៤.-**

មូលនិធិអភិវឌ្ឍន៍ព្រៃឈើជាតិមិនអាចត្រូវយកទៅប្រើប្រាស់សំរាប់ការរៀបចំ និងការប្រព្រឹត្តទៅនៃរដ្ឋបាលព្រៃឈើបានឡើយ ។

មូលនិធិនេះសំរាប់ប្រើប្រាស់ចំពោះតែសកម្មភាពនៃ :

១-ការដាំដើមឈើឡើងវិញ ។

២-កិច្ចការកុក្កវប្បកម្ម និងការស្តារព្រៃឈើឡើងវិញ ។

៣-កិច្ចការពារ និងអភិរក្សព្រៃឈើ និងជីវៈចម្រុះ ។

៤-ការស្រាវជ្រាវបច្ចេកទេស និងវិទ្យាសាស្ត្រនៃព្រៃឈើ និងសត្វព្រៃ ។

៥-ការផ្សព្វផ្សាយអំពីវិស័យព្រៃឈើ និងសត្វព្រៃ ។

៦-ការអភិវឌ្ឍន៍វិស័យព្រៃឈើ និងសត្វព្រៃ ។

៧-ការអភិវឌ្ឍន៍សហគមន៍ព្រៃឈើ ។

៨-ការបណ្តុះបណ្តាលធនធានមនុស្សសម្រាប់វិស័យព្រៃឈើ និងសត្វព្រៃ ។

## ជំពូកទី ១៣

## វិធានការគ្រប់គ្រងសកម្មភាពព្រៃឈើ

**មាត្រា ៦៥.-**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទត្រូវបង្កើតញញួរត្រារដ្ឋបាលព្រៃឈើកម្ពុជាដើម្បី :

១-វាយលើឈើស្របច្បាប់មុនពេលឱ្យដឹកជញ្ជូនចេញពីគំនរក្នុងព្រៃ ។

២-វាយលើឈើដែលជាវត្ថុតាងនៃបទល្មើសព្រៃឈើ ។

ស្នាមញញួរត្រារដ្ឋបាលព្រៃឈើកម្ពុជាមានរាងមូលហើយមានអក្សរកាត់ **រ.ក.**និងលេខនៅពីក្រោមតួអក្សរនោះសម្រាប់សំគាល់ញញួរត្រានីមួយៗ ។

មុននឹងដាក់ឱ្យប្រើប្រាស់ញញួរត្រានេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវធ្វើកំណត់ហេតុផ្តិតស្នាមញញួរត្រានេះ ហើយយកទៅតំកល់ទុកជាគំរូតាងនៅក្រសួងមហាផ្ទៃ និងតុលាការខេត្ត ក្រុង ។

**មាត្រា ៦៦.-**

ញញួរត្រារដ្ឋបាលព្រៃឈើកម្ពុជាត្រូវតែបោះឱ្យបានជិតច្បាស់ដាច់ខាតដោយមន្ត្រីរដ្ឋបាលព្រៃឈើលើរាល់ឈើហ៊ុបដូចតទៅ :

១-ឈើហ៊ុបស្របច្បាប់ដែលត្រូវដឹកជញ្ជូនចេញពីគំនរក្នុងព្រៃរហូតដល់ទីដៅកំណត់ ត្រូវមានស្នាមញញួរត្រារដ្ឋបាលព្រៃឈើកម្ពុជាចំនួនពីបួន (៤) ឡើងទៅកន្លែងនីមួយៗ ខាងគល់ និងខាងចុងឈើហ៊ុប ។

២-ឈើហ៊ុបល្មើសច្បាប់ដែលរដ្ឋបាលព្រៃឈើបានឃាត់ចាប់ត្រូវមានស្លាកញញួរត្រាបី (៣) គឺនៅខាងគល់ កណ្តាល និងខាងចុងឈើហ៊ុបដោយធ្វើឱ្យមានស្លាកបី (៣) រួមគ្នាបង្កើតជារាងត្រីកោណនៅកន្លែងនីមួយៗនោះ ។

ចំពោះដើមឈើដែលត្រូវអនុញ្ញាតអោយកាប់ក្នុងព្រៃបម្រុងទុកអចិន្ត្រៃយ៍ ត្រូវមានស្លាកញញួរត្រារដ្ឋបាលព្រៃឈើកម្ពុជាចំនួនមួយ (១) ជាសំគាល់ ។

ការកាន់កាប់ និងការប្រើប្រាស់ញញួរត្រារដ្ឋបាលព្រៃឈើកម្ពុជា អាចប្រព្រឹត្តទៅបានតែចំពោះមន្ត្រីរដ្ឋបាលព្រៃឈើដែលបានធ្វើសច្ចាប្រណិធាន។ វិធាននៃការគ្រប់គ្រង និងប្រើប្រាស់ញញួរត្រានោះ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា ៦៧.-**

រាល់ព្រៃសម្បទានិក ឬម្ចាស់ព្រៃគុបអាចមានញញួរត្រាឯកជនសម្រាប់វាយលើផលព្រៃឈើរបស់ខ្លួនផ្ទាល់ ប៉ុន្តែស្លាកញញួរត្រាឯកជននេះត្រូវមានរាង ទំហំ និងអក្សរសំគាល់ខុសពីស្លាកញញួរត្រារដ្ឋបាលព្រៃឈើកម្ពុជា ។

មុននឹងយកទៅប្រើប្រាស់ ព្រៃសម្បទានិក ឬម្ចាស់ព្រៃគុបត្រូវបញ្ជាក់សញ្ញាសំគាល់ និងត្រូវផ្តិតស្លាកញញួរត្រានោះ ទៅសុំការអនុញ្ញាតពីប្រធានរដ្ឋបាលព្រៃឈើ និងតម្កល់ទុកជាមុននៅការិយាល័យរដ្ឋបាលព្រៃឈើសាមី ។

**មាត្រា ៦៨.-**

ទោះជាមានលិខិតអនុញ្ញាតស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះក៏ដោយ ក៏ការកាប់ដើមឈើ ការប្រមូល ឬការដឹកជញ្ជូនផល អនុផលព្រៃឈើក្នុងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ត្រូវហាមឃាត់ចាប់ពីម៉ោងប្រាំបី (៨) យប់ដល់ម៉ោង (៥) ភ្លឺ ។

**មាត្រា ៦៩.-**

ផល អនុផលព្រៃឈើគ្រប់ប្រភេទដែលចរាចរក្នុងទូទាំងប្រទេស ត្រូវមានលិខិតអនុញ្ញាតដឹកជញ្ជូនចេញដោយរដ្ឋបាលព្រៃឈើ ។

ផល អនុផលព្រៃឈើគ្រប់ប្រភេទក្រោយពេលបានកាប់រំលំ ត្រូវដឹកជញ្ជូនចេញពីព្រៃឱ្យអស់មកធ្វើសន្និធិនៅគំនរអចិន្ត្រៃយ៍ ក្នុងអំឡុងពេលមិនឱ្យលើសពីមួយ (១) ខែឡើយ និងត្រូវអមដោយលិខិតអនុញ្ញាតដឹកជញ្ជូនចេញដោយរដ្ឋបាលព្រៃឈើ ។

ផល អនុផលព្រៃឈើគ្រប់ប្រភេទដែលជាសន្និធិ ទោះជានៅទីណាក៏ដោយ ក៏ត្រូវអមដោយលិខិតអនុញ្ញាតដឹកជញ្ជូន ឬលិខិតអនុញ្ញាតសន្និធិចេញឱ្យដោយរដ្ឋបាលព្រៃឈើ ។

ការដឹកជញ្ជូនផល អនុផលព្រៃឈើ ឬសន្និធិខុសពីការកំណត់ក្នុងលិខិតអនុញ្ញាត ឬគ្មានលិខិតអនុញ្ញាតដឹកជញ្ជូន ឬ សន្និធិត្រូវចាត់ទុកជាល្មើសច្បាប់ ។

**មាត្រា ៧០.-**

មុនពេលបើកការដ្ឋានប្រមូលផល អនុផលព្រៃឈើប្រចាំឆ្នាំ ព្រៃសម្បទានិក ឬម្ចាស់ព្រៃគុបត្រូវយកគ្រឿងចក្រយានយន្ត និងវណារយន្តគ្រប់ប្រភេទដែលបម្រើឱ្យការប្រមូលផល អនុផលព្រៃឈើ ទៅសុំការអនុញ្ញាតចុះបញ្ជី និងបិទ

ស្លាកជាសំគាល់នៅរដ្ឋបាលព្រៃឈើ ។

គ្រឿងចក្រ យានយន្ត និងរណារយន្តគ្រប់ប្រភេទដែលបំរើឱ្យការប្រមូលផល អនុផលព្រៃឈើដោយពុំបានចុះបញ្ជី និងបិទស្លាកជាសំគាល់របស់រដ្ឋបាលព្រៃឈើ ហើយធ្វើចរាចរក្នុងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ ត្រូវហាមឃាត់ ។

រាល់គ្រឿងចក្រ យានយន្ត និងរណារយន្តគ្រប់ប្រភេទដែលព្រៃសម្បទានិក ឬម្ចាស់ព្រៃគុបស្របច្បាប់មានបំណងធ្វើការនាំចូលដើម្បីបម្រើឱ្យការប្រមូល និងដឹកជញ្ជូនផល អនុផលព្រៃឈើ ត្រូវឆ្លងកាត់ការវាយតម្លៃភាពសមស្របពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

ការប្រើប្រាស់រណារយន្តគ្រប់ប្រភេទដែលបំរើការប្រមូលផល អនុផលព្រៃឈើត្រូវមានការអនុញ្ញាតពីប្រធានរដ្ឋ-បាលព្រៃឈើ ។

**មាត្រា ៧១.-**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទត្រូវកំណត់ដោយប្រកាសនូវចំនួនមូលដ្ឋានឧស្សាហកម្មឈើ រោងចក្រអារឈើ សិប្បកម្មកែ ច្នៃផល អនុផលព្រៃឈើ ដើម្បីធានាបាននូវការផ្គត់ផ្គង់វត្ថុធាតុដើមជាផល អនុផលព្រៃឈើប្រកបដោយនិរន្តរភាព ។

វត្ថុធាតុដើមសម្រាប់មូលដ្ឋានឧស្សាហកម្មឈើ រោងចក្រអារឈើ និងសិប្បកម្មកែច្នៃផល អនុផលព្រៃឈើត្រូវមានប្រភពពីព្រៃសម្បទាន ព្រៃគុប ឈើរឹបអូស ឬពីប្រភពស្របច្បាប់ផ្សេងទៀត ស្របតាមបទប្បញ្ញត្តិនៃច្បាប់ នេះ ។

**មាត្រា ៧២.-**

ការនាំចេញផល អនុផលព្រៃឈើគ្រប់ប្រភេទទៅបរទេស ត្រូវសម្រេចតាមការកំរិតកំណត់ប្រចាំឆ្នាំដោយរាជរដ្ឋាភិបាលតាមសំណើរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

យថាប្រភេទផល អនុផលព្រៃឈើដែលអនុញ្ញាតឱ្យនាំចេញ នាំចូល ត្រូវកំណត់ដោយអនុក្រឹត្យ ។

ការតម្រូវឱ្យមានអាជ្ញាប័ណ្ណនាំចេញ នាំចូលផល អនុផលព្រៃឈើ ត្រូវកំណត់ដោយរាជរដ្ឋាភិបាល ។

**មាត្រា ៧៣.-**

អាជ្ញាប័ណ្ណនាំចេញផល អនុផលព្រៃឈើ ត្រូវផ្តល់ដោយក្រសួងពាណិជ្ជកម្ម និងមានចុះទិដ្ឋាការដោយប្រធានរដ្ឋបាលព្រៃឈើជាមុន ។ ការពន្យារសុពលភាពនៃអាជ្ញាប័ណ្ណនេះត្រូវផ្តល់ដោយក្រសួងពាណិជ្ជកម្ម ។

រាល់ផល អនុផលព្រៃឈើនាំចេញដែលរៀបចំផ្ទុកក្នុងខុនថែនណឺ ចាំបាច់ត្រូវមានការត្រួតពិនិត្យជាមុនដោយមន្ត្រីរដ្ឋបាលព្រៃឈើ និងបិទសំណភ្ជិតមុនពេលអនុញ្ញាតដឹកជញ្ជូនទៅកាន់ឃ្លាំង និងទីលានបញ្ចេញទំនិញពីគយ ។ គំរូសំណបិទភ្ជិតលើខុនថែនណឺផ្ទុកផល អនុផលព្រៃឈើនាំចេញនេះត្រូវកំណត់ដោយប្រកាសក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

ការនាំចេញ នាំចូលផល អនុផលព្រៃឈើត្រូវបង់ពន្ធនាំចេញ នាំចូល និងពន្ធផ្សេងៗទៀតចូលថវិកាជាតិ ។

**មាត្រា ៧៤.-**

ឈើរសាត់តាមខ្សែទឹក កឿង ឬលិចដែលគ្មានដាក់សញ្ញា និងឈើគ្មានម្ចាស់ត្រូវរឹបអូសជាសម្បត្តិរដ្ឋដោយដាក់លក់

ឱ្យដេញថ្លៃជាសាធារណៈ ។

ក្នុងករណីមានបុគ្គលណាមួយទាមទារថា ឈើដូចមានចែងក្នុងកឋាខ័ណ្ឌទី១ ជារបស់ខ្លួននោះ ត្រូវឱ្យបុគ្គលនោះបង្ហាញភស្តុតាងជាក់ស្តែងជាអាទិ៍ លិខិតអនុញ្ញាតប្រមូលផល អនុផលព្រៃឈើ លិខិតអនុញ្ញាតដឹកជញ្ជូន ឬលិខិតអនុញ្ញាតសន្និធិ ក្នុងរយៈពេលសាមសិប (៣០) ថ្ងៃ ចាប់ពីថ្ងៃប្រកាសជូនដំណឹងដោយរដ្ឋបាលព្រៃឈើ ។

ថ្លៃលក់ឈើ ដូចមានចែងក្នុងកឋាខ័ណ្ឌទី១ មាត្រា ៧៤ នៃច្បាប់នេះ ត្រូវបង់ចូលថវិកាជាតិ ។

ក្នុងករណីមានការបាត់បង់ឈើរសាត់តាមខ្សែទឹក កឿង ឬលិច ក៏ដូចជាការបាត់បង់ផល អនុផលព្រៃឈើផ្សេងទៀត ដែលរដ្ឋបាលព្រៃឈើមានសមត្ថកិច្ចបានផ្ញើឱ្យថែរក្សា បុគ្គល ឬអាជ្ញាធរដែលទទួលថែរក្សាត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ ។

**មាត្រា ៧៥.-**

បុគ្គលដែលប្រមូលដឹកជញ្ជូន កែច្នៃ សន្និធិ លក់ដូរ ឬនាំចេញ នាំចូលផល អនុផលព្រៃឈើត្រូវទទួលខុសត្រូវ ក្នុងការបង្ហាញឯកសារដើមស្របច្បាប់នៃផល អនុផលព្រៃឈើដល់មន្ត្រីរដ្ឋបាលព្រៃឈើមានសមត្ថកិច្ចត្រួតពិនិត្យ ។

## ជំពូកទី ១៤

## នីតិវិធីដោះស្រាយបទល្មើសព្រៃឈើ

**មាត្រា ៧៦.-**

បទល្មើសព្រៃឈើ ជាបទល្មើសព្រហ្មទណ្ឌដែលមានចរិតពិសេសដូចមានចែងក្នុងច្បាប់នេះ ។ រដ្ឋបាលព្រៃឈើមានសមត្ថកិច្ចជាមន្ត្រីនគរបាលយុត្តិធម៌ក្នុងការស៊ើបអង្កេតបទល្មើសព្រៃឈើ និងចងក្រងសំណុំរឿងជូនតុលាការ ។

ការស្រាវជ្រាវ ទប់ស្កាត់ បង្ក្រាបបទល្មើសព្រៃឈើជាសមត្ថកិច្ចរបស់រដ្ឋបាលព្រៃឈើគ្រប់ថ្នាក់នៅក្នុងរង្វង់ដែនសមត្ថកិច្ចរៀងៗខ្លួន ។

ប្រតិបត្តិការរបស់មន្ត្រីរដ្ឋបាលព្រៃឈើដែលបានទទួលនីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ ត្រូវអនុវត្តស្របតាមច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ។

**មាត្រា ៧៧.-**

នៅពេលបំពេញបេសកម្មស្រាវជ្រាវ ទប់ស្កាត់ និងបង្ក្រាបបទល្មើសព្រៃឈើ មន្ត្រីរដ្ឋបាលព្រៃឈើត្រូវស្លៀកពាក់ឯកសណ្ឋាន ពាក់សញ្ញាសំគាល់ ពាក់ឋានន្តរសក្តិ និងត្រូវមានលិខិតបញ្ជាបេសកម្ម ។

មន្ត្រីរដ្ឋបាលព្រៃឈើសច្ចាប្រណិធានបំពេញមុខជាមន្ត្រីនគរបាលយុត្តិធម៌បានលុះត្រាតែសាមីខ្លួនបានទទួលនីតិសម្បទាពីអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ។

មន្ត្រីរដ្ឋបាលព្រៃឈើដែលបានទទួលនីតិសម្បទាជានគរបាលយុត្តិធម៌ត្រូវធ្វើ និងចុះហត្ថលេខាលើកំណត់ហេតុបទល្មើសព្រៃឈើតាមដែនសមត្ថកិច្ចរបស់ខ្លួន ។

សំលៀកបំពាក់ឯកសណ្ឋាន សញ្ញាសំគាល់ និងឋានន្តរសក្តិរបស់មន្ត្រីរដ្ឋបាលព្រៃឈើត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៧៨.-**

អាជ្ញាធរដែនដីគ្រប់ថ្នាក់ កងកំលាំងប្រដាប់អាវុធ អាជ្ញាធរគយ និងរដ្ឋាករ អាជ្ញាធរព្រលានយន្តហោះ និងកំពង់ផែ និងអាជ្ញាធរពាក់ព័ន្ធដទៃទៀត ត្រូវបង្កភាពងាយស្រួល និងជួយផ្តល់កំលាំងសហការក្នុងការស្រាវជ្រាវ ទប់ស្កាត់ និងបង្ក្រាបបទល្មើសព្រៃឈើ ឬថែរក្សាវត្ថុតាងបទល្មើសព្រៃឈើជាបណ្តោះអាសន្ន ក្នុងករណីមានការស្នើសុំពីមន្ត្រីរដ្ឋបាលព្រៃឈើមានសមត្ថកិច្ច ។

ក្នុងករណីដែលអាជ្ញាធរទាំងឡាយបានជួបប្រទះនូវបទល្មើសព្រៃឈើជាក់ស្តែងអាជ្ញាធរទាំងនោះ :

១-ត្រូវជូនពតិមានជាបន្ទាន់ដល់មន្ត្រីរដ្ឋបាលព្រៃឈើ ឬការិយាល័យរដ្ឋបាលព្រៃឈើមានសមត្ថកិច្ចដែលនៅជិតបំផុត ។

២-អាចឃាត់ខ្លួនជនប្រព្រឹត្តបទល្មើស និងចាប់ឃាត់វត្ថុតាងបទល្មើសជាបណ្តោះអាសន្ន រួចបញ្ជូនជាបន្ទាន់ទៅមន្ត្រីរដ្ឋបាលព្រៃឈើដែលទទួលនីតិសម្បទាជានគរបាលយុត្តិធម៌ ដើម្បីចាត់ការតាមនីតិវិធី ។

៣-មិនត្រូវប្រមូលប្រាក់ពិន័យ ឬរឹបអូសវត្ថុតាងបទល្មើសដោយផ្ទាល់ឡើយ ។

**មាត្រា ៧៩.-**

ដើម្បីអនុវត្តភារកិច្ចរបស់ខ្លួន មន្ត្រីរដ្ឋបាលព្រៃឈើដែលបានទទួលនីតិសម្បទាជានគរបាលយុត្តិធម៌មានសិទ្ធិ ដូចតទៅ :

១-អាចអោយបុគ្គលណាមួយឆ្លើយតបសំណួរ និងផ្តល់ពតិមានដែលពាក់ព័ន្ធដល់ការប្រព្រឹត្តបទល្មើសព្រៃឈើ

២-ចូលធ្វើការត្រួតពិនិត្យ ឬឆែកឆេរគ្រប់ទីកន្លែងរួមទាំងក្នុងព្រលានយន្តហោះ កំពង់ផែសមុទ្រ កំពង់ផែទន្លេ ផែស្ងួត ច្រកព្រំដែន ចំណតរថយន្ត ស្ថានីយ៍រថភ្លើង ក្នុងករណីបទល្មើសជាក់ស្តែងដោយមានកិច្ចសហការជាមួយសមត្ថកិច្ចជាប់ពាក់ព័ន្ធ ។

៣-ដកហូតជាបណ្តោះអាសន្ននូវអាជ្ញាប័ណ្ណ ឬលិខិតអនុញ្ញាតគ្រប់ប្រភេទដែលកំណត់ដោយច្បាប់នេះ បើសិនជាបុគ្គលទទួលអាជ្ញាប័ណ្ណ ឬលិខិតអនុញ្ញាតនោះប្រព្រឹត្តល្មើសនឹងច្បាប់នេះ ។

ក្នុងករណីបទល្មើសជាក់ស្តែង មន្ត្រីរដ្ឋបាលព្រៃឈើដែលបានទទួលនីតិសម្បទាជានគរបាលយុត្តិធម៌មានសិទ្ធិចូលឆែកឆេរនៅ ក្នុងទីធ្លា អាគារ ឬក្នុងលំនៅដ្ឋានស្របតាមនីតិវិធីព្រហ្មទណ្ឌ ។ ការឆែកឆេរត្រូវធ្វើចំពោះមុខជនជាប់សង្ស័យ និងមានសាក្សីពីរ (២) នាក់ ដែលជាអ្នកជិតខាង ឬអ្នកម្ចាស់ផ្ទះ ។

**មាត្រា ៨០.-**

មន្ត្រីរដ្ឋបាលព្រៃឈើដែលបានទទួលនីតិសម្បទាជានរគបាលយុត្តិធម៌ ក្នុងករណីបទល្មើសជាក់ស្តែងត្រូវចាប់ឃាត់ជាបណ្តោះអាសន្ន :

១-រាល់ផល អនុផលព្រៃឈើ ឬផលប្រមាញ់ ដែលល្មើស និងបទប្បញ្ញត្តិនៃច្បាប់នេះ ។

២-សត្វពាហនៈដែលបានជួបប្រទះកំពុងបំផ្លិចបំផ្លាញដំណាំឈើ ។

៣-គ្រឿងចក្រ យានយន្ត ឧបករណ៍ព្រមទាំងសត្វពាហនៈដែលបានប្រើប្រាស់ជាមធ្យោបាយសម្រាប់ប្រព្រឹត្តបទល្មើសព្រៃឈើ និងសត្វព្រៃ ។

មន្ត្រីរដ្ឋបាលព្រៃឈើដែលបានទទួលនីតិសម្បទាជានគរបាលយុត្តិធម៌ ត្រូវឃាត់ខ្លួនជនប្រព្រឹត្តបទល្មើសព្រៃឈើបានដល់ ៤៨ ម៉ោងយ៉ាងយូរ ដើម្បីបំពេញសំណុំរឿងបញ្ជូនទៅតុលាការ ។

**មាត្រា ៨១.-**

ការកសាងសំណុំរឿងនៃបទល្មើសព្រៃឈើ ត្រូវអនុវត្តតាមច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ។

ទំរង់បែបបទនៃកំណត់ហេតុបទល្មើសព្រៃឈើ ត្រូវកំណត់ដោយប្រកាសរួមរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងយុត្តិធម៌ ។

**មាត្រា ៨២.-**

វត្ថុតាងនៃបទល្មើសព្រៃឈើ ត្រូវបានកំណត់ដូចខាងក្រោម ៖

១-ផល អនុផលព្រៃឈើ ឬផលប្រមាញ់ ដែលជាវត្ថុតាងពិតប្រាកដនៃបទល្មើស ។

២-សម្ភារៈបរិក្ខារ និងមធ្យោបាយដឹកជញ្ជូន ដែលប្រើប្រាស់ក្នុងការប្រព្រឹត្តបទល្មើស ។

វត្ថុតាងដូចមានចែងក្នុងកថាខ័ណ្ឌទី ១ ខាងលើនេះ ត្រូវឃាត់ទុកជាបណ្តោះអាសន្នរហូតដល់សំណុំរឿងនៃបទល្មើសត្រូវបានដោះស្រាយរួចជាស្ថាពរ តាមការបង់ពិន័យអន្តរការណ៍ ឬតាមការជំនុំជំរះរបស់តុលាការ ។

ក្នុងខណៈពេលកំពុងដឹកជញ្ជូនផល អនុផលព្រៃឈើល្មើស ឬផលប្រមាញ់ល្មើស អ្នកបើកបរមធ្យោបាយដឹកជញ្ជូនដែលគ្មានម្ចាស់នៅជាមួយត្រូវឃាត់ខ្លួនជាបណ្តោះអាសន្ន ដើម្បីជាប្រយោជន៍នៃការស៊ើបអង្កេតរកជនល្មើស និងអ្នកសមគំនិត ។

ផលប្រមាញ់ស្រស់ជាអាទិ៍ សត្វរស់ និងសំណាកសត្វព្រៃដែលបានឃាត់ទុកហើយ ងាយខូចខាត ផ្នែករដ្ឋបាលព្រៃឈើមានសិទ្ធិលែង ឬបំផ្លាញចោល ឬរក្សាទុកជាប្រយោជន៍សាធារណៈដោយមានកំណត់ហេតុត្រឹមត្រូវ ។

**មាត្រា ៨៣.-**

មន្ត្រីរដ្ឋបាលព្រៃឈើដែលបានទទួលនីតិសម្បទាជានគរបាលយុត្តិធម៌ត្រូវស្លៀកពាក់ឯកសណ្ឋាន ពាក់សញ្ញាសំគាល់និងពាក់ឋានន្តរសក្តិនៅពេលចូលរួមសវនាការរបស់តុលាការ ។

**មាត្រា ៨៤.-**

នៅរាល់ពេលសវនាការ មន្ត្រីរដ្ឋបាលព្រៃឈើដែលបានទទួលនីតិសម្បទាជានគរបាលយុត្តិធម៌ពាក់ព័ន្ធទៅក្នុងសំណុំរឿងក្តី ត្រូវមានសិទ្ធិឆ្លើយបំភ្លឺអំពីលទ្ធផលនៃការស៊ើបអង្កេតបទល្មើសព្រៃឈើនោះជូនតុលាការ ។

**មាត្រា ៨៥.-**

អាជ្ញាយុកាលនៃបណ្តឹងបទល្មើសព្រៃឈើមាន ៖

១-បទល្មើសព្រៃឈើថ្នាក់ទី១ មានអាជ្ញាយុកាលដប់ប្រាំ (១៥) ឆ្នាំ គិតពីពេលប្រព្រឹត្តបទល្មើស ។

២-បទល្មើសព្រៃឈើថ្នាក់ទី២ មានអាជ្ញាយុកាលប្រាំ (៥) ឆ្នាំ គិតពីពេលប្រព្រឹត្តបទល្មើស ។

៣-បទល្មើសព្រៃឈើថ្នាក់ទី៣ មានអាជ្ញាយុកាលមួយ (១) ឆ្នាំគិតពីពេលប្រព្រឹត្តបទល្មើស ។

ការអនុវត្តន៍អាជ្ញាយុកាលនៃបណ្ដឹងបទល្មើសព្រៃឈើ ត្រូវស្របតាមនីតិវិធីព្រហ្មទណ្ឌ ។

**មាត្រា ៨៦.-**

បុគ្គលដែលប្រព្រឹត្តបទល្មើសព្រៃឈើដូចមានចែងក្នុងច្បាប់នេះ ត្រូវទទួលខុសត្រូវចំពោះសកម្មភាពដែលខ្លួនបានប្រព្រឹត្ត ។

បុគ្គលជាភ្នាក់ងារនៃអង្គភាពរដ្ឋ ឬឯកជនដែលប្រើប្រាស់មធ្យោបាយរបស់អង្គភាពដើម្បីប្រព្រឹត្តបទល្មើសព្រៃឈើ បុគ្គល ឬប្រធានអង្គភាពនោះត្រូវទទួលទោសតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។

បទល្មើសព្រៃឈើដែលប្រព្រឹត្តឡើងដោយបុគ្គល ឬក្រុម ក្រោមការចាត់តាំងរបស់អង្គភាពណាមួយ ប្រធានអង្គភាពនោះត្រូវទទួលទោសតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។

**មាត្រា ៨៧.-**

រូបវន្តបុគ្គលបរទេស ឬនីតិបុគ្គលបរទេសដែលមានបានប្រព្រឹត្តបទល្មើសព្រៃឈើត្រូវស្ថិតនៅក្រោមបទប្បញ្ញត្តិ នៃច្បាប់នេះ ។

**មាត្រា ៨៨.-**

មន្ត្រីរដ្ឋបាលព្រៃឈើដែលមានសមត្ថកិច្ចមានសិទ្ធិអំណាចផ្អាកសកម្មភាពនៅក្នុងតំបន់ព្រៃសម្បទានទាំងមូល ឬមួយផ្នែក មួយរយៈ ដើម្បីចាត់ការតាមនីតិវិធីក្នុងករណីព្រៃសម្បទានិកប្រព្រឹត្តល្មើសនឹងបទប្បញ្ញតិនៃច្បាប់នេះ ឬ ល្មើសនឹងកិច្ចព្រមព្រៀងព្រៃសម្បទានរហូតដល់ដំណោះស្រាយនៃវិវាទត្រូវបានបញ្ចប់ ។

**មាត្រា ៨៩.-**

បុគ្គលណាដែលមិនពេញចិត្តចំពោះការសម្រេចណាមួយ ធ្វើឡើងដោយរដ្ឋបាលព្រៃឈើស្របតាមច្បាប់នេះមានសិទ្ធិប្ដឹងតវ៉ាក្នុងរយៈពេលសាមសិប (៣០) ថ្ងៃយ៉ាងយូរគិតពីថ្ងៃទទួលសេចក្ដីសម្រេចនេះមកប្រធានរដ្ឋបាលព្រៃឈើ ។

ប្រធានរដ្ឋបាលព្រៃឈើត្រូវសម្រេចលើបណ្ដឹងតវ៉ានោះ ក្នុងរយៈពេលសាមសិប (៣០) ថ្ងៃយ៉ាងយូរ ។ ក្រោយពីបានទទួលសេចក្ដីសម្រេចចុងក្រោយលើការពិនិត្យឡើងវិញដោយមានប្រធានរដ្ឋបាលព្រៃឈើ ក្នុងករណីមិនអាចទទួលយកបាន ជននោះអាចធ្វើបណ្ដឹងតវ៉ាទៅតុលាការ ។

ការតវ៉ាក្រោមមាត្រានេះ នឹងមិនធ្វើឱ្យប៉ះពាល់ដល់សិទ្ធិអំណាច និងដំណើរការអនុវត្តន៍ច្បាប់របស់មន្ត្រីរដ្ឋបាលព្រៃឈើមានសមត្ថកិច្ចក្រោមច្បាប់នេះឡើយ ។

## ជំពូកទី ១៥

## បទល្មើសព្រៃឈើ និងទោសប្បញ្ញត្តិ

**មាត្រា ៩០.-**

ទណ្ឌកម្មក្នុងបទល្មើសព្រៃឈើមាន : ទោសជាប់ពន្ធនាគារ រឹបអូសវត្ថុតាង ពិន័យដោយតុលាការ ពិន័យអន្តរ

ករណី ការជួសជុលការខូចខាត ការព្រមាន ការដកហូត ឬការព្យួរកិច្ចព្រមព្រៀង ឬលិខិតអនុញ្ញាត ។

ការពិន័យអន្តរការណ៍លើបទល្មើសព្រៃឈើ ការជួសជុលការខូចខាត និងការព្រមានជាសមត្ថកិច្ចរបស់រដ្ឋបាលព្រៃឈើ ។ ក្នុងករណីជនល្មើសមិនព្រមបង់ប្រាក់ពិន័យអន្តរការណ៍ ឬជួសជុលការខូចខាត រដ្ឋបាលព្រៃឈើអាចបញ្ជូនសំណុំរឿងបទល្មើសទៅតុលាការ ។

ចំពោះមន្ត្រីរាជការដែលប្រព្រឹត្តបទល្មើសព្រៃឈើ ត្រូវទទួលទោសរដ្ឋបាលបន្ថែមលើទោសទណ្ឌដែលមានកំណត់ក្នុងច្បាប់នេះ ។

**មាត្រា ៩១.-**

រដ្ឋបាលព្រៃឈើមានសិទ្ធិសម្រេចពីការពិន័យអន្តរការណ៍លើបទល្មើសព្រៃឈើដូចមានចែងក្នុងមាត្រា ៩០នៃច្បាប់នេះ ។ ការពិន័យអន្តរការណ៍លើបទល្មើសព្រៃឈើអាចធ្វើបានតែក្នុងករណីជនល្មើសសារភាពទោសកំហុស និងយល់ព្រមបង់ប្រាក់ពិន័យស្របតាមទោសប្បញ្ញត្តិនៃច្បាប់នេះ ក្នុងរយៈពេលមិនឱ្យលើសពីដប់ប្រាំ (១៥) ថ្ងៃ គិតពីថ្ងៃចេញសេចក្តីសម្រេច ។

បែបបទ និងសិទ្ធិសម្រេចពិន័យអន្តរការណ៍ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

ក្នុងការកំណត់បរិមាណទឹកប្រាក់ពិន័យអន្តរការណ៍ ត្រូវពិចារណាលើកត្តាដូចតទៅ :

១-ផលប្រយោជន៍សេដ្ឋកិច្ចជាក់ស្តែងពីលទ្ធផលនៃបទល្មើស ។

២-ការខូចខាតដល់បរិស្ថាន ។

៣-ចំនួននៃការប្រព្រឹត្តល្មើស ។

៤-បរិមាណប្រាក់ពិន័យដែលធ្វើឱ្យរាងចាល ។

៥-ការប្រព្រឹត្តល្មើសដោយចេតនា ។

**មាត្រា ៩២.-**

ប្រាក់ពិន័យអន្តរការណ៍ ប្រាក់ពិន័យតាមសាលក្រមតុលាការ ឬប្រាក់បានមកពីការលក់វត្ថុតាង ត្រូវបង់ចូលក្នុងថវិកាជាតិ ។ រាជរដ្ឋាភិបាលអាចសម្រេចផ្តល់រង្វាន់លើកទឹកចិត្តដល់ប្រជាពលរដ្ឋ និងមន្ត្រីដែលបានចូលរួមក្នុងករណីបង្ក្រាបបទល្មើសព្រៃឈើជាក់លាក់ណាមួយ ។

**មាត្រា ៩៣.-**

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនៃច្បាប់នេះ ត្រូវទទួលទណ្ឌកម្មដូចតទៅ :

១-ចំពោះបទល្មើសព្រៃឈើថ្នាក់ទី១ ត្រូវជាប់ពន្ធនាគារពីប្រាំ (៥) ឆ្នាំទៅដល់ដប់ (១០) ឆ្នាំ និងត្រូវរឹបអូសវត្ថុតាងទាំងអស់មកជាសម្បត្តិរដ្ឋ ។

២-ចំពោះបទល្មើសព្រៃឈើថ្នាក់ទី២ ត្រូវជាប់ពន្ធនាគារពីមួយ (១)ឆ្នាំទៅប្រាំ (៥)ឆ្នាំ និង/ឬត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីដប់លាន(១០.០០០.០០០)រៀល ទៅមួយរយលាន(១០០.០០០.០០០)រៀល ។ វត្ថុតាងទាំងត្រូវរឹបអូសមកជាសម្បត្តិរដ្ឋ ។

៣-ចំពោះបទល្មើសព្រៃឈើថ្នាក់ទី៣ ត្រូវជាប់ពន្ធនាគារពីមួយ (១)ខែ ទៅមួយ(១)ឆ្នាំ ឬត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីមួយលាន (១.០០០.០០០) រៀល ទៅដប់លាន (១០.០០០.០០០)រៀល ។ វត្ថុតាងទាំងអស់អាចត្រូវរឹបអូសមកជាសម្បត្តិរដ្ឋ ។

៤-ការព្រមាន ការជួសជុលការខូចខាត ការពិន័យអន្តរការណ៍ ការដកហូត ឬការព្យួរកិច្ចព្រមព្រៀង ឬលិខិតអនុញ្ញាត ។

តម្លៃទីផ្សារជាមូលដ្ឋាននៃផល អនុផលព្រៃឈើត្រូវកំណត់ដោយប្រកាសក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទដើម្បីអនុវត្តនឹងឯកភាពទូទាំងប្រទេស ។

**មាត្រា ៩៤.-**

បុគ្គលណាដែលបានប្រព្រឹត្តបទល្មើសព្រៃឈើធ្វើឱ្យប៉ះពាល់ខូចខាតដល់មជ្ឈដ្ឋានព្រៃឈើត្រូវចេញថ្លៃស្តារ ឬជួសជុលការខូចខាតឱ្យមានលក្ខខណ្ឌដូចដើមឡើងវិញ ។

**មាត្រា ៩៥.-**

រដ្ឋបាលព្រៃឈើអាចចេញលិខិតព្រមាន និងតម្រូវឱ្យជួសជុលការខូចខាតចំពោះសកម្មភាពល្មើសនៅក្នុងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ ដូចខាងក្រោម :

១-ប្រើប្រាស់មធ្យោបាយផ្សេងៗ លែង ឬចងសត្វពាហនៈក្នុងតំបន់ព្រៃបម្រុងទុកអចិន្ត្រៃយ៍ ចំការឈើ ឬថ្នាលកូនឈើរបស់រដ្ឋ ដោយបំផ្លាញឈើ ឬកូនឈើនៅទីនោះ ។

២-ធ្វើឱ្យរបួស ឬធ្វើឱ្យខូចខាតដល់ដើមឈើ ឬរុក្ខជាតិផ្សេងទៀតដែលកំពុងថែរក្សា ឬដែលបានដាំ ។

៣-លួច ឬធ្វើឱ្យខូចខាតដល់របង បង្គោល ឬស្លាកសញ្ញាក្នុងថ្នាលបណ្តុះកូនឈើ ឬក្នុងដែនព្រៃបម្រុងទុកអចិ-ន្ត្រៃយ៍ ។

**មាត្រា ៩៦.-**

ត្រូវទទួលពិន័យអន្តរការណ៍ពីរដ្ឋបាលព្រៃឈើជាប្រាក់ចំនួនពី ពីរ (២)ទៅបី(៣)ដង នៃតម្លៃវត្ថុតាងពិតប្រាកដនៃទីផ្សារ ចំពោះជនណាដែលបានប្រព្រឹត្តបទល្មើសណាមួយដូចខាងក្រោម :

១-កាប់ដើមឈើដែលគ្មានស្លាកសញ្ញាសំគាល់អនុញ្ញាតឱ្យកាប់រំលំ ។

២-ដឹកជញ្ជូនផល អនុផលព្រៃឈើដោយគ្មានលិខិតអនុញ្ញាត ។

៣-ធ្វើសន្និធិផល អនុផលព្រៃឈើដោយគ្មានលិខិតអនុញ្ញាត ។

៤-ដឹកជញ្ជូនផល អនុផលព្រៃឈើខុសទិសដៅលើសបរិមាណកំណត់ក្នុងលិខិតអនុញ្ញាតដឹកជញ្ជូន ។

៥-ប្រើប្រាស់លិខិតអនុញ្ញាតដឹកជញ្ជូនផល អនុផលព្រៃឈើហួសសុពលភាព ។

៦-មានយថាប្រភេទផល អនុផលព្រៃឈើខុសពីការកំណត់ក្នុងលិខិតអនុញ្ញាតដឹកជញ្ជូន ។

៧-ធ្វើសន្និធិផល អនុផលព្រៃឈើលើសពីលិខិតអនុញ្ញាត ។

៨-នាំចេញផល អនុផលព្រៃឈើ គ្រាប់ពូជ និងប្រភេទរុក្ខជាតិព្រៃដែលលើសពីការកំណត់ក្នុងអាជ្ញាប័ណ្ណ ។

៩-កាប់រំលំ អារ ច្រៀក និងចាំងឈើមូលក្នុងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ ឬប្រើរណារយន្តជាមធ្យោបាយ ប្រមូលផលព្រៃឈើដោយគ្មានលិខិតអនុញ្ញាត ឬគ្មានស្លាកសញ្ញា ។

១០-ប្រមូលផល អនុផលព្រៃឈើក្រៅម៉ោងអនុញ្ញាត ។

១១-ដឹកជញ្ជូនផល អនុផលព្រៃឈើដែលកាប់រំលំ ឬប្រមូលយកមកដោយផ្ទុយនឹងបទប្បញ្ញត្តិនៃច្បាប់នេះ ។

១២-ផល អនុផលព្រៃឈើដែលយកមកកែច្នៃ ត្រូវបានកាប់ ឬប្រមូលដោយផ្ទុយនឹងបទប្បញ្ញត្តិនៃច្បាប់នេះ

១៣-ផល អនុផលព្រៃឈើគ្រប់ប្រភេទដែលលក់ដូរ ចែកចាយបានមកពីការកាប់ ឬរុករក ដឹកជញ្ជូន កែច្នៃ ដែលផ្ទុយនឹងបទប្បញ្ញត្តិនៃច្បាប់នេះ ។

១៤-ផល អនុផលព្រៃឈើគ្រប់ប្រភេទដែលបានមកពីការប្រមូលផល ដឹកជញ្ជូន កែច្នៃ ដោយផ្ទុយនឹងបទប្បញ្ញត្តិនៃច្បាប់នេះ ។

១៥-នាំចេញផល អនុផលព្រៃឈើដែលអាជ្ញាប័ណ្ណគ្មានចុះទិដ្ឋាការដោយប្រធានរដ្ឋបាលព្រៃឈើ ។

១៦-ចិញ្ចឹម បង្កាត់ពូជប្រភេទសត្វព្រៃក្នុងក្រុមជិតផុតពូជ ។

១៧-យកធ្វើកម្មសិទ្ធិ កែច្នៃសំណាក សន្និធិ ដឹកជញ្ជូន ឬនាំចូលសត្វព្រៃរស់ និងសំណាកក្នុងក្រុមមានដោយកម្រ ។

១៨-ចិញ្ចឹម បង្កាត់ពូជប្រភេទសត្វព្រៃក្នុងក្រុមមានដោយកម្រ ។

១៩-ដឹកជញ្ជូន ធ្វើពាណិជ្ជកម្ម សន្និធិ កែច្នៃសំណាក ឬនាំចូលសត្វព្រៃរស់ និងសំណាកក្នុងក្រុមមានដោយបង្គួរ ដោយគ្មានលិខិតអនុញ្ញាត ។

២០-បរបាញ់ក្នុងទីសាធារណៈ ។

ជនណាប្រព្រឹត្តបទល្មើសដូចមានចែងក្នុងកថាខ័ណ្ឌទី១ នៃមាត្រានេះ មិនរាងចាលក្នុងរយៈពេលមួយ (១)ខែ ត្រូវទទួលការពិន័យអន្តរការណ៍ពីរដ្ឋបាលព្រៃឈើជាប្រាក់ចំនួន ពីពីរ (២)ទៅបួន (៤) ដង នៃតម្លៃវត្ថុតាងពិតប្រាកដនៃទីផ្សារ ។

វត្ថុតាងពិតប្រាកដនៃបទល្មើសព្រៃឈើ ត្រូវរឹបអូសជាសម្បត្តិរដ្ឋស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។ វត្ថុតាងផ្សេងទៀតក្រៅពីផល អនុផលព្រៃឈើ អាចប្រគល់ឱ្យសាមីជនវិញតែក្នុងករណីប្រព្រឹត្តល្មើសនឹងមាត្រា ៩៦នៃច្បាប់នេះ ។

**មាត្រា ៩៧.-**

ត្រូវផ្តន្ទាទោសក្រោមបទល្មើសព្រៃឈើថ្នាក់ទី១ ដែលត្រូវជាប់ពន្ធនាគារពីប្រាំ (៥)ឆ្នាំ ទៅដប់ (១០)ឆ្នាំ និងត្រូវរឹបអូសវត្ថុតាងទាំងអស់មកជាសម្បត្តិរដ្ឋ ដកហូតកិច្ចព្រមព្រៀង អាជ្ញាប័ណ្ណ លិខិតអនុញ្ញាត និងកំទេចចោលវត្ថុតាងក្លែង ចំពោះជនណាដែលបានប្រព្រឹត្តបទល្មើសណាមួយដូចខាងក្រោម :

១-ក្លែងញញួរត្រា ឬប្រើញញួរត្រាក្លែង ឬបំផ្លាញស្នាមញញួរត្រារដ្ឋបាលព្រៃឈើដែលវាយលើឈើហ៊ុប ។

២-ក្លែងបន្លំដោយស្លៀកពាក់ឯកសណ្ឋាន ពាក់សញ្ញាសម្គាល់ ឬពាក់ឋានន្តរសក្តិរបស់មន្ត្រីរដ្ឋបាលព្រៃឈើ ។

៣-ក្លែងបន្លំលិខិតសាធារណៈដែលពាក់ព័ន្ធនឹងវិស័យព្រៃឈើ ឬសត្វព្រៃ ។

៤-បំផ្លាញ លាក់បាំង លក់ ឬលួចវត្ថុតាងព្រៃឈើ ។

៥-កំទេច ផ្លាស់ប្តូរ លុបបំបាត់ ឬធ្វើឱ្យខូចខាតដល់ព្រំសីមានៃតំបន់ព្រៃឈើ ។

៦-កាប់រានព្រៃ ឈូសឆាយដីព្រៃ ហ៊ុំព័ទ្ធកាន់កាប់ព្រៃឈើ ។

៧-បង្កឱ្យភ្លើងឆេះព្រៃដោយចេតនា ។

៨-គ្រៀវ បំពុល កាប់បំផ្លាញ ផ្តួលរំលំដើមឈើ ឬគាស់រំលើងប្រមូលគល់ឈើ ។

៩-បង្កើតមូលដ្ឋានកែច្នៃវល្លិ៍រមៀត ឬមូលដ្ឋានសិប្បកម្មអនុផលព្រៃឈើផ្សេងទៀតដែលនាំមកនូវការបំផ្លាញព្រៃឈើ និងមជ្ឈដ្ឋានព្រៃឈើ ។

១០-បរបាញ់ សម្លាប់ ធ្វើពាណិជ្ជកម្ម ឬនាំចេញប្រភេទសត្វក្នុងក្រុមជិតផុតពូជ ។

ជនណាប្រព្រឹត្តបទល្មើសព្រៃឈើថ្នាក់ទី១ មិនរាងចាល ត្រូវផ្តន្ទាទោសទ្វេដងនៃបទល្មើសព្រៃឈើថ្នាក់ទី ១ នៃច្បាប់នេះ ។

**មាត្រា ៩៨.-**

ត្រូវផ្តន្ទាទោសក្រោមបទល្មើសព្រៃឈើថ្នាក់ទី ២ ដែលត្រូវជាប់ពន្ធនាគារពីមួយ (១)ឆ្នាំ ទៅប្រាំ (៥)ឆ្នាំ និងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីដប់លាន (១០.០០០.០០០)រៀល ទៅមួយរយលាន (១០០.០០០.០០០)រៀល ឬផ្តន្ទាទោសណាមួយនៃទោសទាំងពីរ វត្ថុតាងទាំងអស់ត្រូវរឹបអូសមកជាសម្បត្តិរដ្ឋ ចំពោះជនណាដែលបានប្រព្រឹត្តបទល្មើសណាមួយដូចខាងក្រោម :

១-មិនគោរពតាមបទបញ្ជាបច្ចេកទេសដែលបានកំណត់ក្នុងក្រមបច្ចេកទេសអនុវត្តគ្រប់គ្រងព្រៃឈើកម្ពុជា ។

២-មិនគោរពផែនការគ្រប់គ្រង និងផែនការប្រមូលផល អនុផលព្រៃឈើប្រចាំឆ្នាំ ។

៣-យកលិខិតអនុញ្ញាតប្រើប្រាស់ព្រៃឈើទៅប្រមូលផល អនុផលព្រៃឈើ ។

៤-ប្រើប្រាស់គ្រឿងចក្រ យានយន្តបម្រើឱ្យការប្រមូលផល អនុផលព្រៃឈើដោយគ្មានលិខិតអនុញ្ញាត ឬគ្មានស្លាកសំគាល់ ។

៥-គាស់កកាយយកថ្ម ដី ខ្សាច់ រ៉ែ ដែលមាននៅក្នុងដីនៃដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ ។

៦-ប្រើប្រាស់ព្រៃឈើលើសពីទំហំអនុញ្ញាត ឬគ្មានលិខិតអនុញ្ញាត ដើម្បីស្ថាបនាផ្លូវសាធារណៈ ផ្លូវព្រៃឈើ ឬដាក់តាំងមូលដ្ឋានសំណង់ ឬលំនៅដ្ឋានគ្រប់ប្រភេទតាមដងផ្លូវ ។

៧-បង្កើតមូលដ្ឋានឧស្សាហកម្មឈើ រោងចក្រអារឈើ សិប្បកម្មកែច្នៃផល អនុផលព្រៃឈើ ប្រភេទធំ និងមធ្យមដោយគ្មានប្រកាស ។

៨-បង្កើតឡគ្រប់ប្រភេទ ដែលប្រើប្រាស់ផល អនុផលព្រៃឈើជាវត្ថុធាតុដើមដោយគ្មានលិខិតអនុញ្ញាត ។

៩-បរបាញ់ក្នុងរដូវកាលហាមឃាត់ ឬក្នុងតំបន់ការពារ ។

១០-បរបាញ់ សម្លាប់ ធ្វើពាណិជ្ជកម្ម ឬនាំចេញប្រភេទសត្វក្នុងក្រុមមានដោយកម្រ ។

១១-បរបាញ់សត្វព្រៃដោយប្រើមធ្យោបាយដែលបង្កគ្រោះថ្នាក់ដល់ជីវសាស្ត្រសត្វ ។

១២-យកធ្វើជាកម្មសិទ្ធិ កែច្នៃសំណាក សន្និធិ ដឹកជញ្ជូន ឬនាំចូលប្រភេទសត្វរស់ និងសំណាកក្នុងក្រុមជិតផុតពូជ ។

ត្រូវផ្តន្ទាទោសក្រោមបទល្មើសព្រៃឈើថ្នាក់ទី ២ ដែលត្រូវជាប់ពន្ធនាគារពីមួយ(១)ឆ្នាំ ទៅប្រាំ (៥)ឆ្នាំ និងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ចំនួនពីដប់លាន(១០.០០០.០០០.)រៀល ទៅមួយរយលាន(១០០.០០០.០០០)រៀល វត្ថុតាងទាំងអស់ត្រូវរឹបអូសមកជាសម្បត្តិរដ្ឋ ចំពោះជនណាដែលបានប្រព្រឹត្តបទល្មើសណាមួយដូចខាងក្រោម :

១-ប្រមូលផល អនុផលព្រៃឈើដោយគ្មានលិខិតអនុញ្ញាត ។

២-ប្រមូលផល អនុផលព្រៃឈើក្រៅដែនព្រៃគុបកំណត់ក្នុងលិខិតអនុញ្ញាត ឬក្រៅភូមិសាស្ត្រដែលកំណត់ក្នុងផែនការប្រមូលផល អនុផលព្រៃឈើប្រចាំឆ្នាំ ។

៣-ផ្ទេរសិទ្ធិ ឬលក់អាជ្ញាប័ណ្ណ ឬលិខិតអនុញ្ញាតគ្រប់ប្រភេទដោយគ្មានការអនុញ្ញាត ។

៤-កាប់ដើមឈើក្នុងចំការដាំឈើរបស់រដ្ឋ ។

៥-ប្រមូលផល អនុផលព្រៃឈើ ចំពោះប្រភេទឈើជាប់លំដាប់ថ្នាក់ដែលមិនទាន់ដល់ទំហំអប្បបរមាអនុញ្ញាតឱ្យកាប់រំលំ ប្រភេទឈើដែលមានដោយកម្រ ប្រភេទឈើដែលប្រជាជនចោះយកជ័រតាមប្រពៃណី និងប្រភេទឈើផ្តល់ជ័រមានតម្លៃ ។

៦-នាំចូលគ្រាប់ពូជរុក្ខជាតិព្រៃគ្រប់ប្រភេទ ដោយគ្មានទិដ្ឋាការពីអាជ្ញាធរវិទ្យាសាស្ត្ររបស់ប្រទេសនាំចេញ និង គ្មានការអនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

៧-នាំចេញផល អនុផលព្រៃឈើដែលគ្មានអាជ្ញាប័ណ្ណ ។

ជនណាប្រព្រឹត្តបទល្មើសព្រៃឈើថ្នាក់ទី ២ មិនរាងចាល ត្រូវផ្តន្ទាទោសក្រោមបទល្មើសព្រៃឈើថ្នាក់ទី ១នៃច្បាប់នេះ ។

**មាត្រា ៩៩.-**

ត្រូវផ្តន្ទាទោសក្រោមបទល្មើសព្រៃឈើថ្នាក់ទី ៣ ដែលត្រូវជាប់ពន្ធនាគារពីមួយ (១)ខែ ទៅមួយ(១)ឆ្នាំ ឬត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីមួយលាន (១.០០០.០០០)រៀលទៅដប់លាន (១០.០០០.០០០)រៀល វត្ថុតាងទាំងអស់អាចត្រូវរឹបអូសមកជាសម្បត្តិរដ្ឋ ចំពោះជនណាដែលបានប្រព្រឹត្តបទល្មើសណាមួយ ដូចខាងក្រោម :

១-ប្រើប្រាស់រណារយន្តគ្រប់ប្រភេទដែលបំរើការប្រមូលផល អនុផលព្រៃឈើដោយគ្មានការអនុញ្ញាតពីប្រធានរដ្ឋបាលព្រៃឈើ ។

២-នាំចូលគ្រឿងចក្រ យានយន្ត និងរណារយន្តគ្រប់ប្រភេទសម្រាប់ការប្រមូលផល អនុផលព្រៃឈើ ដោយគ្មានការវាយតម្លៃភាពសមស្របពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

៣-នាំចេញផល អនុផលព្រៃឈើដែលគ្មានសំណាបិទភ្ជិតរបស់រដ្ឋបាលព្រៃឈើលើខ្លួនថែនណឺ ។

៤-យាយី ធ្វើឱ្យរបួស ប្រមូលពង កូននៃប្រភេទសត្វក្នុងក្រុមជិតផុតពូជ ឬក្រុមមានដោយកម្រ ឬបំផ្លាញជម្រករបស់វា ។

៥-បង្កើតរោងសន្និធិ លក់ដុំ រាយ នូវផល អនុផលព្រៃឈើ និងសិប្បកម្មកែច្នៃផល អនុផលព្រៃឈើប្រភេទតូចដោយគ្មានលិខិតអនុញ្ញាត ឬផ្ទុយពីការកំណត់ ។

៦-បង្កើតមូលដ្ឋានឧស្សាហកម្មឈើ រោងចក្រអារឈើ សិប្បកម្មកែច្នៃផល អនុផលព្រៃឈើ ឬឡគ្រប់ប្រភេទដែលប្រើប្រាស់ ឬមិនប្រើប្រាស់ផល អនុផលព្រៃឈើជាវត្ថុធាតុដើម ឬជាប្រភពថាមពលខុសពីទីតាំងកំណត់ដោយរដ្ឋបាលព្រៃឈើ ។

ជនណាប្រព្រឹត្តបទល្មើសព្រៃឈើថ្នាក់ទី ៣ មិនរាងចាល ត្រូវផ្តន្ទាទោសក្រោមបទល្មើសព្រៃឈើថ្នាក់ទី ២ នៃច្បាប់នេះ ។

**មាត្រា ១០០.-**

សកម្មភាពទាំងឡាយណាដែលធ្វើឡើងដោយមន្ត្រីអាជ្ញាធរដែនដី មន្ត្រីនគរបាល មន្ត្រីនៃកងយោធពលខេមរភូមិន្ទ ឬមន្ត្រីអាជ្ញាធរផ្សេងទៀត ដើម្បីធ្វើអន្តរាគមន៍ ផ្តល់ការអនុញ្ញាតដោយផ្ទាល់ ឬដោយប្រយោលជួយដល់អាជីវកម្មព្រៃឈើ និងធ្វើសកម្មភាពគ្រប់យ៉ាងផ្ទុយនឹងបទប្បញ្ញត្តិនៃច្បាប់នេះ ឬធ្វើការគំរាមកំហែងដល់មន្ត្រីរដ្ឋបាលព្រៃឈើ ឬ រាំងស្ទះដល់ការបំពេញភារកិច្ច និងកិច្ចប្រតិបត្តិការរបស់មន្ត្រីរដ្ឋបាលព្រៃឈើ ត្រូវចាត់ទុកជាបទល្មើសដែលត្រូវផ្តន្ទាទោសជាប់ពន្ធនាគារពីមួយ (១) ឆ្នាំ ទៅប្រាំ (៥) ឆ្នាំ និងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ចំនួនពីដប់លាន (១០.០០០.០០០) រៀលទៅមួយរយលាន(១០០.០០០.០០០) រៀល ។

**មាត្រា ១០១.-**

ចំពោះសកម្មភាពដូចខាងក្រោម ដែលប្រព្រឹត្តឡើងដោយមន្ត្រីរដ្ឋបាលព្រៃឈើត្រូវចាត់ទុកជាបទល្មើសនិងត្រូវផ្តន្ទាទោសជាប់ពន្ធនាគារពីមួយ (១) ឆ្នាំ ទៅប្រាំ (៥) ឆ្នាំ និងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីដប់លាន (១០.០០០.០០០) រៀល ទៅមួយរយលាន (១០០.០០០.០០០) រៀល :

១-ផ្តល់ការអនុញ្ញាតណាមួយដែលផ្ទុយនឹងបទប្បញ្ញត្តិនៃច្បាប់នេះ ។

២-ចូលរួមទាំងស្រុង ឬដោយផ្នែក និងដោយផ្ទាល់ ក្នុងសកម្មភាពណាមួយនៃអាជីវកម្មព្រៃឈើដែលផ្ទុយនឹងបទប្បញ្ញត្តិនៃច្បាប់នេះ ។

៣-អនុគ្រោះចំពោះបទល្មើសព្រៃឈើណាមួយ ។

៤-ប្រកបរបរអាជីវកម្មណាមួយពាក់ព័ន្ធនឹងវិស័យព្រៃឈើ ទោះធ្វើជាម្ចាស់ទាំងស្រុងក្តី ជាម្ចាស់ភាគហ៊ុនក្តី ឬធ្វើជានិយោជិក ឬអ្នកធានាឱ្យអ្នកដទៃក្តី ក្នុងអំឡុងពេលកំពុងកាន់តំណែង ឬក្នុងអំឡុងពេលមួយ (១) ឆ្នាំ ក្រោយពីការឈប់កាន់តំណែងដោយប្រការណាក៏ដោយ ។

៥-មិនបានរាយការណ៍ ឬមិនបានដាក់ពាក្យបណ្តឹងចំពោះបទល្មើសព្រៃឈើថ្នាក់ទី ១ ដែលបានកើតក្នុងរង្វង់សមត្ថកិច្ចរបស់ខ្លួនទាន់ពេលវេលា ។

៦-ធ្វេសប្រហែសដោយចេតនាក្នុងការបំពេញភារកិច្ច ឬផ្តល់ពតិមាននូវរបាយការណ៍ក្លែងបន្លំជាលាយលក្ខណ៍អក្សរដែលជាមូលហេតុបង្កឱ្យកើតមានបទល្មើសព្រៃឈើថ្នាក់ទី ១ ។

## ជំពូកទី ១៦

## ការអនុវត្តសាលក្រមតុលាការ

### មាត្រា ១០២.-

ការអនុវត្តន៏សាលក្រម ឬសាលដីកាស្ថាពរនៃបទល្មើសព្រៃឈើ ជាភារកិច្ចរបស់រដ្ឋបាលព្រៃឈើមានសមត្ថកិច្ច លើកលែងតែទោសជាប់ពន្ធនាគារ ។

### មាត្រា ១០៣.-

រាល់សម្រង់សាលក្រម ឬសាលដីកានៃបទល្មើសព្រៃឈើត្រូវចម្លងមួយច្បាប់ជូនរដ្ឋបាលព្រៃឈើមានសមត្ថកិច្ច ។

### មាត្រា ១០៤.-

បន្ទាប់ពីសាលក្រម ឬសាលដីកាចូលជាស្ថាពរ វត្ថុតាងដែលបានរឹបអូសបានត្រូវចាត់ចែងតាមនីតិវិធីដោយរដ្ឋបាលព្រៃឈើ ។

## ជំពូកទី ១៧

## អន្តរប្បញ្ញត្តិ

### មាត្រា ១០៥.-

ព្រៃសម្បទានទាំងឡាយ ទោះជាមានស្រាប់នៅមុនពេលច្បាប់នេះចូលជាធរមានក្តី ឬបានផ្តល់ឱ្យក្រោយៗមកទៀត តាមការដាក់ឱ្យដេញថ្លៃជាសាធារណៈ ដូចមានចែងក្នុងមាត្រា ១៣ នៃច្បាប់នេះក្តី ព្រៃសម្បទានិកត្រូវចុះកិច្ចព្រមព្រៀងព្រៃសម្បទាន តាមគំរូថ្មីតែមួយជា មូលដ្ឋាន ។

### មាត្រា ១០៦.-

នៅទីណាដែលរដ្ឋបាលព្រៃឈើមានភស្តុតាងបញ្ជាក់ថា ការកាន់កាប់ដីព្រៃណាមួយបានមកពីការកាប់រានដីព្រៃឈើរដ្ឋដោយខុសច្បាប់មុនច្បាប់នេះចូលជាធរមាន រដ្ឋបាលព្រៃឈើមានសិទ្ធិចេញលិខិតជូនដំណឹងក្នុងនាមរាជរដ្ឋាភិបាលជាម្ចាស់កម្មសិទ្ធិលើដីព្រៃឈើរដ្ឋដោយធ្វើការបណ្តេញ និងទាមទារកម្មសិទ្ធិដីព្រៃឈើរដ្ឋមកវិញដោយឥតលក្ខខណ្ឌ ។

### មាត្រា ១០៧.-

នៅពេលច្បាប់នេះចូលជាធរមាន រោងចក្រ និងសិប្បកម្មកែច្នៃផល អនុផលព្រៃឈើទាំងឡាយដែលបានបង្កើតឡើង និងកំពុងដំណើរការក្រោមប្រកាសអនុញ្ញាតរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ត្រូវបានផ្ទេរឱ្យ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

សិប្បកម្មកែច្នៃផល  អនុផលព្រៃឈើទាំងនោះ  ត្រូវបានអនុញ្ញាតឱ្យបន្តសកម្មភាពរហូតដល់ផុតសុពលភាពនៃប្រកាស ។

ចំពោះរោងចក្រកែច្នៃផល អនុផលព្រៃឈើត្រូវបំពេញបែបបទសុំបន្តផលិតកម្ម អាជីវកម្មស្របតាមនីតិវិធីដូចមានចែងក្នុងច្បាប់នេះ ក្នុងរយៈពេលប្រាំមួយ (៦) ខែ គិតពីច្បាប់នេះចូលជាធរមាន ។

## ជំពូកទី ១៨
## អវសានប្បញ្ញត្តិ

**មាត្រា ១០៨.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ១០៩.-**

ច្បាប់នេះត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញ, ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០២

ក្នុងព្រះបរមនាម និងតាមព្រះរាជបញ្ជាបង្គាប់

**ប្រមុខរដ្ឋស្ដីទី**

នស/រកម/០៨០២/០២៧២ **ហត្ថលេខា និងត្រា**

**ជា ស៊ីម**

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្ថលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

បានជម្រាបជូនសម្ដេចនាយករដ្ឋមន្ត្រី

**រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**ហត្ថលេខា**

**ចាន់ សារុន**

លេខ : ១៨២ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ,ថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ ២០០២

**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**